ឧត្តមប្រឹដា ចាប-ពិន

# ក្បួនច្បាប់ការ អាពាហ៍ ពិពាហ៍



បណ្ណាគារ

CA16

# ក្បួនទម្រង់ការ
# អាពាហ៍ពិពាហ៍

ឧត្តមប្រឹជា ចាប-ពិន និពន្ធបណ្ឌិត
អតីតអធិបតីក្រុមជំនុំទំនៀមទម្លាប់ខ្មែរ
នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង តាមក្បួនបុរាណ

ការផ្សាយរបស់
បណ្ណាគារ
សេង.ងួន.ហួត

ភ្នំពេញ

ព.ស. ២៥០៨

គ.ស. ១៩៦៥

# បញ្ជីរឿង

| រឿង | ទំព័រ |
| --- | --- |
| ក្បួនទម្រង់ការ អាពាហ៍ពិពាហ៍ . . | ១ |
| ពិធីអាពាហ៍ពិពាហ៍ មានរបៀបធំៗ៨ ថ្នាក់. . | ១ |
| ១– របៀបមើលសមពង្សឆ្នាំ . . . | ២ |
| ២– របៀបមើលសមពង្សធាតុ . . . | ៧ |
| ៣– របៀបចែចូវ . . . . . . . | ១០ |
| ៤– របៀបដណ្ដឹង . . . . . . . | ១៥ |
| ៥– របៀបជូនពាណា . . . . . . | ៤២ |
| ៦– របៀបបន្តាប់ . . . . . . . | ៥៥ |
| ៧– របៀបអាពាហ៍ពិពាហ៍មង្គល . . | ៦០ |
| ៨– របៀបផ្សំដំណេក . . . . . . | ៩៩ |
| អាពាហ៍ពិពាហ៍មង្គលសង្ខេប . . | ១០២ |

# ក្បួនទម្រង់ការ
# អាពាហ៍ពិពាហ៍

តាមប្រពៃណីនៅមជ្ឈិមប្រទេស (ឥណ្ឌា) សម័យបុរាណ ពិធីមង្គលការកូន មាន ២ យ៉ាង គឺនាំកូនស្រីទៅរៀបការនៅផ្ទះខាងប្រុស ហៅ អាវាហមង្គល ១ នាំកូនប្រុសទៅរៀបការនៅផ្ទះខាងស្រី ហៅ វិវាហមង្គល ១ ។

ឯប្រពៃណីខ្មែរ តែងនាំកូនប្រុសទៅរៀបការនៅផ្ទះខាងស្រីតែមួយយ៉ាង ជាទម្លាប់តាំងពីព្រេងនាយរៀងមក តែហៅគួបទាំងពីរយ៉ាងថា អាពាហ៍ពិពាហ៍មង្គល ។

ទីនេះ សូមពណ៌នាដោយពិស្តារ អំពីអាពាហ៍ពិពាហ៍មង្គល តាមក្បួនទម្រង់ការខ្មែរបុរាណ ដូចតទៅ :

## ពិធីអាពាហ៍ពិពាហ៍មង្គលខ្មែរ មានរបៀបធំៗ ៨ ថ្នាក់

១– របៀបមើលសមពង្សឆ្នាំ

២– របៀបមើលសមពង្សធាតុ

៣– របៀបចែចូវ

៤– របៀបដណ្តឹង

៥– របៀបជូនពេលា

៦– របៀបបង្គាប់

៧– របៀបអាពាហ៍ពិពាហ៍មង្គល

៨– របៀបផ្សំដំណេក

## ពណ៌នាសេចក្តី

### ១ របៀបមើលសមតផ្សឆ្នាំ

អ្នកគ្រប់គ្រងកូនកម្លោះ កាលបើបានឃើញកូនក្រមុំរបស់ជនណាដែលទីពេញចិត្តហើយ តែងសុំសួររកថ្ងៃខែឆ្នាំកំណើតរបស់នាងនោះ យកមកឲ្យហោរគន់គូរមើលផ្សំនឹងថ្ងៃខែឆ្នាំកំណើតកូនប្រុសរបស់ខ្លួន បើផ្សំទៅហើយឃើញល្អ គេក៏គិតគូរចូលទៅស៊ីដណ្តឹង ។ ចំណែកខាងអ្នកគ្រប់គ្រងកូនស្រីក៏ដូចគ្នា កាលបើមានជនណាមកដណ្តឹងកូនស្រីរបស់ខ្លួន គេក៏យកថ្ងៃខែឆ្នាំកូនប្រុសនោះមកឲ្យហោរគន់គូរមើលដែរ បើ

ឃើញថាល្អទើបគេឲ្យ ។ របៀបគន់គូមើលនោះ លោកហៅថាមើលសមពង្សឆ្នាំ ដូចខាងមុខនេះ :

ឆ្នាំរបស់ខ្មែរមានឈ្មោះហៅតាមជាតិរបស់សត្វទាំង ១២ គឺ ជូត - កណ្ដុរ , ឆ្លូវគោ , ខាល - ខ្លា , ថោះ - ទន្សាយ , រោង - នាគ , ម្សាញ់ - ពស់ , មមី - សេះ , មមែ - ពពែ , វក - ស្វា , រកា - មាន់ , ច - ឆ្កែ , កុរ - ជ្រូក ។

ក្នុងឆ្នាំទាំង ១២ នោះ ចែកចេញជាសមពង្សមាន ៣ ពួក ក្នុងមួយពួក ៗ មាន ៤ ឆ្នាំ គឺ

អ្នកកើតឆ្នាំ ថោះ - កុរ - ឆ្លូវ - ម្សាញ់ មួយពួក ជាសមពង្សមនុស្ស ។

អ្នកកើតឆ្នាំមមី - មមែ - រោង - ជូត មួយពួក ជាសមពង្សទេវតា ។

អ្នកកើតឆ្នាំ វក - ខាល - ច - រកា មួយពួក ជាសមពង្សយក្ស ។

អ្នកដែលយកគ្នាជាប្ដីប្រពន្ធ លោកថាត្រូវឲ្យមើលសម-ពង្សឆ្នាំ សមពង្សជាតុជាដើម ត្រូវរើសយកតែអ្នកដែលត្រូវសមពង្សជាមួយគ្នា ឬដែលមិនជាត្រូវនឹងគ្នា ឬដែលមានឫទ្ធិដូចគ្នា ល្មមទូទាត់គ្នាបាន ដូចផ្លូវឲ្យមើលតទៅនេះ ៖

ឆ្នាំមមី - មមែ ពង្សទេវតាស្រី , ឆ្នាំជូត - ឆ្លូវ ពង្សទេវតាប្រុស ដូច្នេះនៅជាមួយគ្នាល្អណាស់ ស្រឡាញ់គ្នាណាស់ នឹងមានកូនច្រើន ។

ជូតនឹងមមី ជូតនឹងមមែ ឆ្លូវនឹងមមី ឆ្លូវនឹងមមែ ៤ យ៉ាងនេះស្រឡាញ់គ្នាណាស់ មានកូនច្រើនបានសុខជានិច្ច ។

ជូតនឹងឆ្លូវ ពង្សទេវតាប្រុស ដូចគ្នា ល្អ ។

មមីនឹងមមែ ពង្សទេវតាស្រី ដូចគ្នា ជាមធ្យម ។

ខាល - ចរ ពង្សយក្សស្រី រកា - វក ពង្សយក្សប្រុសនៅជាមួយគ្នាល្អដែរ មានកូនច្រើន តែច្រើនឈ្លោះប្រកែកគ្នា ។

ខាលនឹងរកាល្អ ។ ខាលនឹងវកជាមធ្យម ។ ចរនឹងរកាជាមធ្យម

វកនឹងចរល្អណាស់ ។ ខាលនឹងចរ ច្រើនប្រកួតក្ដីគ្នា ។ រកានឹងវកល្អ ។

មមីនឹងមមែពន្សទេវតាស្រី , ឆ្លូវនឹងម្សាញ់ ពន្សមនុស្សប្រុស ដូច្នេះ នៅជាមួយគ្នាល្អតែខាងដើម ដល់ចាស់ច្រើនបែកគ្នា ។ ឆ្លូវនឹងមមីល្អណាស់ ។ ឆ្លូវនឹងមមែល្អ ។ ម្សាញ់នឹងមមី បិត្តជាមួយគ្នា ។ ម្សាញ់នឹងមមែល្អណាស់ ។

ឆ្លូវនឹងរោង ឆ្លូវនឹងជូត ពន្សមនុស្សប្រុសនៅជាមួយគ្នាច្រើនមិនសូវឃ្លាតគ្នា ។ ម្សាញ់នឹងរោង ម្សាញ់នឹងជូតអាក្រក់ ។

ថោះនឹងកុរ ពន្សមនុស្សស្រី , ជូតនឹងរោង ពន្សទេវតាប្រុសជាមធ្យម មានព្រាត់គ្នាហើយជួបគ្នាវិញ ។ ថោះនឹងមមី , ថោះនឹងមមែអាក្រក់ ។ កុរនឹងមមែ អាក្រក់ ។ ថោះនឹងកុរ ជាមធ្យម ។

ខាលនឹងចរ ពន្សយក្ខស្រី , ជូតនឹងរោង ពន្សទេវតាប្រុស ដូច្នេះនៅជាមួយគ្នាជាមធ្យម មិនសូវឃ្លាតគ្នា ។ ជូតនឹងខាល

ល្អណាស់ ៗ ពេលនឹងខាលអាក្រក់ ៗ ពេលនឹងច មិនល្អ ៗ ចនឹងមមី ចនឹងមមែ ខាលនឹងមមី ខាលនឹងមមែ ៤ យ៉ាងនេះ ពាក្យទេវតាស្រី នឹងយក្សស្រីមិនល្អ ច្រើនប្រច័ណ្ឌ នឹងវិវាទគ្នា ៗ

មមី នឹងមមែ ពាក្យទេវតាស្រី រកានឹងវក ពាក្យយក្សប្រុសនៅជាមួយគ្នាជាបង្សម មានកូន តែច្រើនឈ្លោះគ្នា ៗ រកានឹងមមីគ្រាន់បើ ៗ វកនឹងមមី ជាកណ្ដាល ៗ រកានឹងពេង , រកានឹងជូត , វកនឹងពេង , វកនឹងជូត ៤ យ៉ាងនេះពាក្យទេវតាប្រុសនឹងទេវតាស្រី មិនសូវល្អច្រើនប្រកួតប្រជ្ជិគ្នា ៗ

ឋោះនឹងកុរ ពាក្យមនុស្សស្រី រកានឹងវក ពាក្យយក្សប្រុស ៗ មនុស្សស្រីយក្សប្រុស នៅជាមួយគ្នាល្អតែដំបូង ដល់ចាស់នឹងព្រាត់គ្នាមិនល្អ ៗ វកនឹងឋោះអាក្រក់ ៗ វកនឹងកុរគ្រាន់បើ ៗ រកានឹងឋោះគ្រាន់បើ ៗ រកានឹងកុរ រកានឹងឆ្លូវ វកនឹងឆ្លូវ វកនឹងម្សាញ់ ៤ យ៉ាងនេះពាក្យយក្សប្រុស នឹង

មនុស្សប្រុស ច្រើនវិវាទគ្នាញយ ៗ មិនល្អ ។

ខាលនឹងច ពង្សយកស្រី , ឆ្លូវនឹងម្សាញ់ពង្សមនុស្សប្រុស មនុស្សនឹងយកស្រី ដាមធ្យម ល្អខាងដើម ដល់ចាស់ ចុងនឹងព្រាត់គ្នា ។ ឆ្លូវនឹងខាល ល្មមសមគួរ ។ ឆ្លូវនឹងចដា កណ្តាល ។ ម្សាញ់នឹងខាលល្អ ។ ម្សាញ់នឹងច ដាបង្គួរ ។ ខាលនឹងកុរ ខាលនឹងថោះ ចនឹងថោះ ចនឹងកុរ ៤ យ៉ាងនេះ ពង្សយកស្រី នឹងមនុស្សស្រីមិនល្អ ច្រើនមានទោសនឹងគ្នា ។

## ២– របៀបមើលសមពង្សធាតុ

ឆ្នាំជូត ធាតុទឹក , ឆ្លូវធាតុដី , ខាលធាតុឈើ , ថោះធាតុឈើ រោងធាតុមាស ម្សាញ់ធាតុភ្លើង មមីធាតុភ្លើង មមែធាតុមាស វកធាតុដែក រកាធាតុដែក ចធាតុដី កុរធាតុទឹក ។

ប្រុសធាតុដី ស្រីធាតុដី នៅជាមួយគ្នាល្អណាស់ ។

ប្រុសធាតុភ្លើង ស្រីធាតុទឹក កាលដើមមិនល្អច្រើនឈ្លោះគ្នា ដល់ចាស់ល្អអាយុច្រើនយឺន ។ ប្រុសធាតុឈើ ស្រីធាតុទឹក

ល្អណាស់នៅជាមួយគ្នាត្រូវជាក់ចិត្ត  តែចិញ្ចឹមកូនមិនសូវគង់ ។ ប្រុសធាតុឈើ ស្រីធាតុដែក នៅជាមួយគ្នាមិនបានយូរ ។ ប្រុសធាតុដែក ស្រីធាតុដី នៅជាមួយគ្នាល្អនឹងមានសម្បត្តិ ។ ប្រុសធាតុដី ស្រីធាតុដែក នៅជាមួយគ្នានឹងមានកូនច្រើន ។ ប្រុសធាតុដែក ស្រីធាតុទឹក នៅជាមួយគ្នាល្អណាស់ ។ ប្រុសធាតុដែក ស្រីធាតុឈើ នៅជាមួយគ្នាល្អ នឹងបានជាមន្ត្រី ។ ប្រុសធាតុទឹក ស្រីធាតុដី នៅជាមួយគ្នាត្រូវជាក់ចិត្ត ។ ប្រុសធាតុទឹក ស្រីធាតុភ្លើងល្អ តែច្រើនប្រចណ្ឌគ្នា ។ ប្រុសធាតុទឹក ស្រីធាតុដែក ល្អណាស់នឹងបានជាមន្ត្រី ។ ប្រុសធាតុទឹក ស្រីធាតុដី នឹងស្រឡាញ់គ្នាណាស់ ។ ប្រុសធាតុឈើ ស្រីធាតុភ្លើង នឹងមានកូនប្រុសហើយព្រាត់គ្នា ។ ប្រុសធាតុដី ស្រីធាតុភ្លើង ដល់ចាស់នឹងបានល្អ មានទ្រព្យច្រើន ។ ប្រុសធាតុដី ស្រីធាតុទឹក នៅជាមួយគ្នា ១ ឆ្នាំ នឹងបានល្អ នឹងមានអ្នកឧបត្ថម្ភ ។ ប្រុសធាតុភ្លើង ស្រីធាតុភ្លើងនឹងកំសត់ណាស់ ។ ប្រុស

ធាតុភ្លើង ស្រីធាតុដី នៅជាមួយគ្នាបាន ៧ ឆ្នាំនឹងព្រាត់គ្នា ។ ប្រុសធាតុឈើ ស្រីធាតុឈើ មិនល្អ ។ ប្រុសធាតុឈើ ស្រីធាតុដីស្រឡាញ់គ្នាតែតោងព្រាត់គ្នា ។ ប្រុសធាតុភ្លើង ស្រីធាតុដែក ខ្សត់សម្បត្តិណាស់ ។ ប្រុសធាតុដែក ស្រីធាតុភ្លើង ច្រើនវិវាទគ្នា ។ ប្រុសធាតុភ្លើង ស្រីធាតុឈើ ច្រើនវិវាទគ្នា ។ ប្រុសធាតុដែក ស្រីធាតុដែកល្អណាស់នៅសុខសន្តគ្នា ។ ប្រុសធាតុឈើ ស្រីធាតុដីមិនសូវល្អ ។ ប្រុសធាតុដែក ស្រីធាតុដីល្អ ។ ចំណែកឯធាតុមាសនោះលោកថាគ្មានទាស់ទៀយ នោះបើនឹងចូលដោយធាតុអ្វីក៏បានទាំងអស់ ។

សន្មតជាចប់វិធីមើលសមពង្សឆ្នាំ នឹងសមពង្សធាតុដោយសង្ខេបតែប៉ុណ្ណោះ រីឯមិនមែនអស់តម្រាមើលប៉ុណ្ណោះទេ នៅមានតម្រាងទៀតជាច្រើនដែលគេតែងមើល ដូចយ៉ាងតម្រាសមពង្សនាគ ឬដែលហៅថា សុភាក្លិក, តម្រាមេកមាស តម្រាអត្ថៈ, តម្រា១២ រាសីដើម តែសូមឲ្យជ្រាបថា តម្រាមើល

អំបាលនេះមិនមែនសុទ្ធតែត្រូវ តាមដោយទំនាយទុកទាំងអស់នោះទេ មានខុសខ្លះ ត្រូវខ្លះជាធម្មតា ។ ពួកអ្នកជឿតម្រាអំបាលនេះ កាលគេពិនិត្យទៅហើយឃើញល្អ ទើបចាត់មនុស្សឱ្យទៅចែចូវ ដូចមានរៀបរាប់តទៅនេះ ៖

## ៣- របៀបចែចូវ

ក្នុងការៈដំបូង មាតាបិតា ឬអាណាព្យាបាលកូនប្រុសកាលពិនិត្យមើលគំនិតមារយាទ នឹងពិនិត្យមើលតាមតម្រាអំបាលនេះ ឃើញគួរសមនឹងចិត្តរបស់ខ្លួនហើយ រមែងពឹងរកមនុស្សដែលជាញាតិ ឬដែលធ្លាប់ស្និទ្ធស្នាលនឹងមាតាបិតា ឬអាណាព្យាបាលខាងកូនស្រីជាអ្នកដែលមានគូស្រករ ដោយមានខាន់ស្លា ហើយមានជីវិតរស់នៅទាំងពីរ ជាអ្នកមានសតិបញ្ញាស្គាល់ខុសត្រូវ ខ្ពស់ទាប ជាអ្នកមានវាចាច្រើនទៀងត្រង់ បានពីរនាក់ឱ្យទៅសួរនិយាយចែចូវ គឺនិយាយស្ទាបស្ទង់មើលសិន អស់ការៈ ៣ ដង ។

អ្នកនាំការនេះ តាមភាសាបុរាណហៅថា អ្នកចែចូវ ក៏មានមេអណ្ដើកក៏មាន ឈ្នួយក៏មាន ។

ក)- ជើងដំបូងត្រូវមានរបស់កំដរដៃទៅបន្តិចបន្តួច ដូចយ៉ាងស្លា ម្លូ ថ្នាំ ខ្ចប់យកទៅកាលទៅដល់ហើយត្រូវស្រាយយករបស់អំបាលនោះ ដាក់ទៅប្រអប់ស្លាដែលគេយកមកដាក់ទទួលខ្លួន និយាយសន្ទនាប្រាស្រ័យគ្នានូវគ្នាពីនេះពីនោះតាមសមគួរហើយ ត្រូវនិយាយពីផ្លូវបញ្ឆិតបញ្ឆៀងថា លោកអ្នកឈ្មោះនោះនិយាយនឹងខ្ញុំថាបេះតែតឹករលឹកអាល័យចង់មកលេងនឹងលោក .អ្នកឯណោះ តើលោកអ្នកនឹងមានប្រសាសន៍ដូចម្ដេចះតែជឿថាលោក.អ្នកគង់ជាមិនរង្កៀស គង់ជាអនុញ្ញាត្តឲ្យទៅមក ។

មាតា - បិតា ឬអាណាព្យាបាលកូនស្រីត្រូវតបថា ការត្រង់នោះស្រេចនូវចិត្តលោក .អ្នកឯណោះ ខ្ញុំមិន

ហ៊ានអារកាត់ឲ្យដាច់ខាតទៅទេ តែសូមជ្រាបថា បើទុកជាអញ្ជើញមក ខ្ញុំក៏គ្មានវត្ថុអ្វីដ៏សមគួរនឹងជូនដែរ តែប៉ុណ្ណោះហើយ អ្នកបំរើត្រូវណាត្រឡប់ទៅវិញ ។

១)- ជើងជាគំរប់ពីរ ក្នុងជើងគំរប់ពីរនេះរបៀបខាងដើមក៏ដូចគ្នានឹងជើងដំបូង ប្លែកតែក្នុងជើងនេះ ត្រូវនិយាយថា លោក-អ្នកឈ្មោះនេះ បានពឹងខ្ញុំឲ្យមកជំរាបថា ចង់មកលេងនឹងលោក-អ្នកឯណោះខ្លាំងណាស់ ដោយឮដំណឹងថា លោក-អ្នកមានស្រែស្រុក សំបុកជើងលាន ស្រឡាញ់ចូលចិត្តចង់យកពូជស្រូវគង់មកបណ្ដុះក្រុងប្រកបមានផ្លែផ្កា រក្សាវង្សត្រកូលតទៅ តើលោកអ្នកនឹងមានប្រសាសន៍ដូចម្ដេច ?

មាតា - បិតា ឬអាណាព្យាបាលត្រូវតបថា ស្រែនោះ ទោះបីអាក្រក់ល្អខ្ញុំមានមែនតែដែលលោកអ្នកឯណោះ

គិតយកពូជស្រូវគង់មកបណ្ដុះនោះ ក្រែងប្រកបគ្នា ៗ មួយទៀត អ្នករួមសម្បត្តិផងគ្នាក៏មានច្រើន ក្រែងគេបំរុងពូជធារនឹងបណ្ដុះដែរ ក៏មិនអាចដឹងបាន សុំឲ្យបង្អង់ចាំស្ដាប់មើលទៅនាយគង់ជានឹងដឹង ៗ

តែប៉ុណ្ណោះហើយ អ្នកចែចូវត្រូវត្រឡប់មកវិញ ។

គ)- ជើងជាគំរប់បី ក្នុងជើងជាគំរប់បីនេះ អ្នកសាមីដើមការត្រូវចាត់រកស្លាម្លូ ឲ្យបានក្រៃលជាងជើងមុនៗ ដាក់តោក ឬរង ១ គូ ប្រគល់ឲ្យអ្នកចែចូវកាន់យកទៅជាកំដរដៃដូចមុន ទៅដល់ហើយលើកជូនទៅមាតា-បិតា ឬអាណាព្យាបាលកូនស្រី ហើយជំរាបតាមដំណើរថា កាលខ្ញុំមកជើងមុនលោក-អ្នកមានប្រសាសន៍ថា ស្រែជើងស្រុករបស់លោក-អ្នកនោះ មានអ្នករួមសម្បត្តិផងគ្នាច្រើនក្រែងគេបម្រុងពូជធារនឹងបណ្ដុះដែរ ក៏តែឥឡូវនេះលោក

អ្នកឯណោះឲ្យមកជំរាបថា សូមបិត្តលោកអ្នកម្តង ដោយប៉ងមកយូរហើយថា នឹងយកពូជស្រូវគង់ខាងឯណោះមកបណ្តុះ តើលោកអ្នកនឹងទុកផូវឲ្យដើរ ទុកដំណើរឲ្យឡើងដែរ ឬដូចម្តេច? សូមប្រសាសន៍ ។

*មាតា-បិតាឬអាណាព្យាបាលកូនស្រី បើបម្រុងនឹងឲ្យគប្បីតបថា* សេចក្តីនេះស្រេចនូវលោកឯណោះសប្បុរសស្មោះបិត្តផងគ្នា ខ្ញុំនឹងឃាត់ទៅឃើញដូចមិនសម នឹងបង្ខំឲ្យមកឃើញដូចជាមិនគួរ ឲ្យទៅជំរាបលោកឯណោះវិញចុះថា ផ្លូវគេតែងតែដើរ ដំណើរគេតែងតែឡើង ។ *លំដាប់នោះអ្នកចែចូវត្រូវដណ្តឹងសួរអំពីថ្ងៃខែឆ្នាំកំណើតរបស់នាងជាកូនស្រី ។ មាតា-បិតាឬអាណាព្យាបាលត្រូវប្រាប់ជាកិច្ចដើម្បីសិរីសួស្តីថា ៖* កូនយើងកើតថ្ងៃមាស ខែប្រាក់ ឆ្នាំសិរីទ្ធិ ហើយត្រូវប្រាប់ឈ្មោះ

ថ្ងៃខែឆ្នាំតាមត្រង់មួយសារទៀត ។ ប៉ុណ្ណោះហើយ អ្នកចែចូវត្រូវត្រឡប់មកវិញ ។

របៀបចែចូវដែលពោលមកនេះ សូមប្រាប់ថាជាបែប១ ដែលគេតែងតែប្រើនិយាយមកហើយជាច្រើន តែមិនមែនសុទ្ធតែប្រើនិយាយមួយបែបប៉ុណ្ណោះ គន់មានពាក្យនិយាយទៅផ្សេងៗ តែលំនាំសេចក្ដី ប្អក្ដរសប្រហែលៗ គ្នានេះ ។

មួយទៀត អ្នកដែលពាក់ពាយជាញាតិនឹងគ្នា ឬដែលស្និទ្ធស្នាលនឹងគ្នា គេមិនបាច់និយាយចែចូវស្ទាបស្ទង់ដល់ទៅពាដនឹងប្រុះទេ គេនិយាយដោយខ្លួនគេដោយត្រង់ៗ ចំៗ តែម្ដងក៏មានច្រើន ។

## ៤- របៀបដណ្ដឹង

### ក) ជើងទី ១

កាលឲ្យមនុស្សទៅនិយាយចែចូវ ឬនិយាយដោយខ្លួនឯងផ្ទាល់ក្រោយថា គេមុខជាព្រមលើកឲ្យកូនគេហើយ លុះដាច់

នោះត្រូវគិតគូរទៅដណ្ដឹងតទៅទៀតតាមទំនៀម តែមុននឹងទៅដណ្ដឹង ត្រូវចាត់បំរើម្នាក់ឲ្យទៅជូនពត៌មានដល់អ្នកគ្រប់គ្រងកូនស្រីថា លោកអ្នកឈ្មោះនោះ នៅស្រុកខេត្រឈ្មោះនោះ នឹងឲ្យអ្នកផ្ញើរមកប្រណិប័តន៍សូមដណ្ដឹងកូនស្រីលោក-អ្នក ៣ ជើង តាមទំនៀមស្រុកដូច្នេះ តើលោកអ្នកនឹងមេត្តាអនុញ្ញាតឲ្យមកនៅថ្ងៃណាខែណា? សូមមានប្រសាសន៍ជាដំណឹង ។

មេបាខាងស្រីត្រូវកំណត់ថ្ងៃ ខែ តាមដែលឃើញថា ជាថ្ងៃមង្គលល្អហើយងាយស្រួល ទៅឲ្យអ្នកសាមីដើមការវិញ កាលដល់ថ្ងៃខែនោះហើយ អ្នកសាមីដើមការ ត្រូវពឹងរកស្រី ៣ នាក់ ដែលជាអ្នកមានគុណសម្បត្តិដូចពោលមកហើយក្នុងរៀនចែចូវ ឲ្យទៅដណ្ដឹង ។ ស្រីអ្នកចំណាងខ្លួនទៅដណ្ដឹងកូនគេនោះ តាមភាសាស្រុកហៅថា «អ្នកជូរ» ហើយត្រូវចាត់

ការរៀបរណ្ដាប់ភស្ដុភារបណ្ណាការគ្រឿងជណ្ដឹងតាមទំនៀម ក្នុងពិធីជាដំបូង គឺ:

១– ស្លា ៨ ដៃ

២– ម្លូ ១២ ត្របក

៣– ប្នាំ ៨ ដុំ

៤– ស្លាជ្លា ៨ ដុំ

របស់អំពាលនេះឲ្យរៀបដាក់រង ១ គូ ៗ

៥– ចេកទុំ ២ តោក

៦– អន្សម ២ –

៧– នំគម ២ –

៨– នំបត់ ២ –

ប្រគល់ឲ្យអ្នកផ្ញើនាំទៅកាន់ត្រកូលខាងស្រី ។ ចំណែកឯខាងស្រីក្នុងថ្ងៃនោះ ត្រូវរៀបចំផ្ទះសម្បែងឲ្យស្អាតសម្រាប់ទទួលអ្នកផ្ញើ ហើយនឹងអញ្ជើញពួកញាតិរបស់ខ្លួន ចំនួន

ប្រមាណ ២ នាក់ ៣ នាក់ ឲ្យមកជួបជុំក្នុងវេលានោះដើម្បី
នឹងឲ្យជួយស្តាប់ការផង ។

អ្នកផ្ញើកាលទៅដល់ហើយ គប្បីនិយាយជាពាក្យសុភាព
ជា : លោកអ្នកឈ្មោះនោះ នៅភូមិ ស្រុក ខេត្តនោះ
បានពឹងរកខ្ញុំទាំង ៣ នាក់ ឲ្យជាអ្នកផ្ញើនាំភស្តុភារស្លា
ម្លូមកជូនសូមដណ្តឹងនាងឈ្មោះនោះជាកូនលោកអ្នក
នោះ ឲ្យជាភរិយាឈ្មោះនាយនោះ ជាកូនរបស់
លោកសាមីដើមការ បើលោកអ្នកមេត្តាឲ្យទាន និង
បានលើកគ្រឿងបណ្ណាការជូនពិសាតាមត្រូវការ ។

មាតា - បិតានឹងពួកមេបាគប្បីតបថា ដែលអ្នកផ្ញើ
មានប្រសាសន៍មកអម្បាញ់មិញ ពេញជាពិរោះហើយ
យើងជាមេបាមិនទាល់ក្រអ្វីទេ តែបើកូនយើងនៅ
ក្មេងសេចក្តី ខ្វះច្បាប់សណ្តាប់ស្រុក ពុំទាន់ចេះធ្វើ

ការរកស៊ីនៅឡើយ ពុំទាន់គួរនឹងទុកដាក់ឲ្យមានប្តី យើងទុកប្រដៅឲ្យចេះធ្វើការរកស៊ី និងទំនៀមទម្លាប់ សណ្តាប់ស្រុកសិន មិនគួរនឹងឲ្យអ្នកឯណោះមកភព ប្រសប់ផងទេ ។

*អ្នកផ្ញើរនិយាយសសោះអន្ទងថា :* បើលោកអ្នកទប់ ប្រឡាយ សុំស្រាយរបង បើលោកអ្នកទាត់ជើងស្តាំ សុំខ្ទបជើងឆ្វេង បើកូនលោកអ្នកនៅក្មេង យូរទៅ គង់តែចេះលែងតែលោកអ្នកមេត្តាឲ្យទានចុះ ។

*ពួកមេបាត្រូវស្នងសារទៅវិញ* អ្នកលោមគង់តែបាន អង្គ អ្នកដេញចង់ឲ្យតែទាន់ អ្នករត់បង់ឲ្យតែរួច អ្នក មកញាយៗ បាយអស់ឆ្នាំងនៅ រឿងនេះបើយើងមិន ទទួលហាក់ដូចស្សាជិន នឹងបណ្តេញទៅហាក់ដូច

មិនគួរ ដូច្នេះសុំឲ្យរង់ចាំយើងសួរមេបាជិតឆ្ងាយសិ

បើឧស្សាហ៍ទៅមកជើងក្រោយគង់តែនឹងដឹង

ចំណោះឈ្មោះថា បានផ្លូវ ១ ជើងហើយ អ្នកផ្លូវត្រូវលើ

ភ័ស្តុភារស្លាម្លូជូនទៅមេបាតាមទំនៀម ។

## ១- ជើងជាគំរប់ពីរ

### ស៊ីស្លាកន្សែង

កាលឲ្យអ្នកផ្លូវទៅដណ្ដឹង ១ ជើងហើយ ឃើញថាគេ

ភាន់អនុញ្ញាតឲ្យដាច់ស្រេចនៅឡើយ គ្រាន់តែបើកផ្លូវឲ្យដើរ

ទៅទៀត ដូច្នេះ អ្នកសាមីដើមការក៏ត្រូវគិតគូរទៅដណ្ដឹងតទៅ

ទៀតតាមទំនៀម ក្នុងឱកាសណាមួយដ៏សមគួរ ។ តែមុននឹង

ឲ្យអ្នកផ្លូវទៅដណ្ដឹង ត្រូវជូនដំណឹងទៅដល់ខាងស្រី ដូចពោល

ហើយ ក្នុងជើងជាដំបូង កាលបានកំណត់ថ្ងៃខែមកហើយ

ត្រូវចាត់រណ្ដាប់ ស្លាកន្សែង គឺរង ១ មានកន្សែងបញ្ចពណ៌

( កន្ទេលមានសម្បុរ ៥ យ៉ាង ) ឬកន្ទេលប្រូប៊ុច ១ ក្រាលលើរងនោះហើយរៀបគ្រឿងស្លាគ្រប់មុខដាក់លើកន្ទេលនោះ និងរៀបបណ្ដាការគ្រឿងដណ្ដឹងតាមទំនៀមគឺ :

១– ស្លា = ១៦ ដៃ

២– ម្លូរ = ១៤ ត្របក

៣– ថ្នាំ = ១៦ ដុំ

៤– ស្លាថ្នាំ = ១៦ ដុំ

៥– ទៀន = ១ គូ

៦– ស្រា = ២ ស៊ីក (គឺ២ដប)

របស់អំបាលនេះឲ្យញែកដាក់ទង ១ គូ ។

៧– ចេកទុំ ២ តោក

៨– អន្សម ២ –

៩– នំគម ២ –

១០– នំបង់ឆ្នាញ់ ២ –

កាលរៀបរណ្ដាប់បានស្រេចយ៉ាងនេះហើយ ត្រូវប្រគល់ឲ្យអ្នកផ្ទូវនាំទៅកាន់ត្រកូលខាងស្រី ។ ចំណែកឯខាងស្រីក្នុងថ្ងៃនោះ ក៏ត្រូវអញ្ជើញញាតិសន្ដានជិតខាងរបស់ខ្លួនឲ្យមកជួបជុំដូចមុន ។ អ្នកផ្ទូវទៅដល់ហើយគប្បីថ្លែងថា សូមជំរាបអស់លោកមេបាធំ-តូច សូមជ្រាបដ្បិតអ្នកសាមីដើមការបានពឹងពារកខ្ញុំឲ្យមក សូមដណ្ដឹងកូនស្រីលោកមេបាមួយជើងមុនហើយ ដូចលោកមេបាទាំងពួងជ្រាបស្រាប់ហើយឥឡូវនេះក៏បានពឹងពារកខ្ញុំទាំង ៣ នាក់ឲ្យនាំភស្តុភារបណ្ណាការស្លាម្លូមក សូមចងពន្ធជាសាច់សន្ដានស្ពានមេត្រី ជាប់ពូជរួមពង្សវង្សញាតិជាមួយគ្នាតទៅ ដោយសូមដណ្ដឹងនាងឈ្មោះនោះជាកូនលោកមេបា ឲ្យជាភរិយាឈ្មោះនាយនោះ ជាកូន

អ្នកសាមីដើមការ បើលោកមេបាះមត្តាឲ្យទាននឹងបាន
លើកស្លាកស្នៀងជូនពិសា ជាគ្រឿងសំគាល់សេចក្តី
ជាប់សម្ពន្ធមេត្រីតទៅ ហើយនឹងបានលើកគ្រឿង
បណ្តាការអំបាលនេះជូនពិសាទៀតតាមត្រូវការ ។

ពួកមេបាត្រូវតបជា យើងសព្វថ្ងៃក៏ត្រូវការរកតែ
ញាតិសន្តានព្រៀងលានសម្មាយ ក្រែងជួនដើរយប់-
ព្រឹកជិតឆ្ងាយនឹងបានចូលសំណាក់ភ័ករអាស្រ័យ តែ
ជាវេលានេះ យើងជាមេបានឹងទុកដាក់តែម្តង យើញ
ពុំទាន់គួរការ ប្រការ ១ អ្នកជាអ្នកផ្ញើនេះជាភេទស្រី
ភាព ក្រែងទទួលគ្រប់ជំពូកអំពីយើងជាមេបាពុំបាន
ប្រការ ២ ដោយយើងជាមេបាវល់គ្នា ពុំទាន់បាន
ឃើញរូបឆោមលោមពណ៌ នឹងពុំទាន់បានដឹងគំនិត

មារយាទរបស់កូនប្រុសអ្នក ដូច្នេះសូមឲ្យអ្នកផ្ញើរវិល
ទៅជំរាបអ្នកសាមីដើមការ ឲ្យពឹងរកបុរសដែលជា
អ្នកមានពូជពង្សល្អជាអ្នកមានគូស្រករដោយមានខាន់
ស្លាហើយនៅរស់ទាំងពីរ ជាអ្នកមានសតិបញ្ញាស្គាល់
រាក់ជ្រៅត្រូវខុសខ្ពស់ទាប ឲ្យមកនិយាយការនឹងយើង
ជាមេបា ទាំងឲ្យនាំខ្លួនកូនប្រុសមកឲ្យយើងពិនិត្យ
មើលផង បើឃើញគួរសមហើយយើងក៏មិនថាអ្វី ។

លំដាប់នោះអ្នកផ្ញើរលើកស្លាកន្សែង ជូនទៅពួកមេបាពិសាទូ-
ទៅគ្រប់គ្នា(មានទំនៀមថា ពួកមេបាដែលពិសាស្លា ត្រូវបៀក
មួម្ដង២សន្លឹកដើម្បីជាប្រផ្នូលឲ្យកម្លោះក្រមុំទាំងពីរនោះបានជា
គូគ្នា ) ហើយនឹងលើកគ្រឿងបណ្ដាការស្លាម្លូជូនទៅទៀត ។
ប៉ុណ្ណេះឈ្មោះថា បានផ្លូវជាគីរប់ពីរជើងហើយ ។

ការដណ្តឹងកូនក្រមុំរបៀបនេះ ហៅតាមកិរិយាដែលស៊ីស្លាដែលភ្ជាប់ដោយកន្សែងដាក់លើវានោះថា "ស៊ីស្លាកន្សែង" បើហៅតាមរូប គួរហៅថា "ស៊ីស្លាតូចបញ្ជាប់ពាក្យ" ឬហៅថា "បញ្ជាប់ពាក្យតូច" ដូច្នេះក៏បាន ។

## គ) ជើងជាគំរប់បី

### ស៊ីស្លាបញ្ជាប់ពាក្យ

អំណើះ អំពីនោះមក អ្នកសាមីដើមការ ត្រូវគិតគូរទៅដណ្តឹង ឲ្យបានជាដាច់ស្រេចតទៅ ។ មុននឹងទៅត្រូវជូនពត៌មានទៅដល់ខាងស្រីដូចមុន ។ ចំណែកឯខាងស្រីសោត ក៏ត្រូវកំណត់ថ្ងៃខែ ឲ្យមក នឹងត្រូវរៀបចំគេហដ្ឋាន នឹងអញ្ជើញពួកញាតិសន្តានសាច់សាលោហិតឲ្យមកកាន់ទីសន្និបាតក្នុងផ្ទះនោះ ឲ្យបានចំនួនច្រើនជាងជើងមុន ១ ព្រោះជើងនេះជាការសំខាន់ ដែលត្រូវអនុម័តិ ឬបដិសេធឲ្យដាច់ខាតទៅថាត្រូវឲ្យឬត្រូវឃាត់ខាង នេះជាកិច្ចរបស់ពួកញាតិដែលជាក្រុមប្រឹក្សា

ត្រូវសម្រេចដោយព្រមព្រៀងគ្នានឹងមាតា-បិតាឬអាណាព្យាបាល ។ អ្នកសាមីដើមការកាលបានដំណឹងកំណត់ថ្ងៃខែមកហើយត្រូវពឹងរកអ្នកជួរ ៣ នាក់ ដូចមុន និងប្រុស ៣ នាក់ទៀត គឺរកបុរសដែលមានគុណសម្បត្តិដូចដែលមេបាបង្គាប់មកខាងលើនេះ ឲ្យបាន ២ នាក់តាមប្រក្រតី គេច្រើនយកអ្នកដែលធ្លាប់ធ្វើការនោះមានកេរ្តិ៍ឈ្មោះមកហើយ និងក្មេងប្រុសជំទង់ ១ នាក់ទៀត ឲ្យជាអ្នកកាន់គ្រឿងប្រដាប់សម្រាប់អ្នកដណ្តឹងនោះ ប្រុសអ្នកដណ្តឹង ៣ នាក់នេះហៅតាមភាសាស្រុកថា "អ្នកមហា" ហើយត្រូវរៀបរណ្តាប់កស្តុភារបណ្តាការឲ្យមានចំនួនច្រើនជាងពីមុន ។ តាមបែបដែលលោកកំណត់ទុកមកនោះ ដូច្នេះ គឺ ,

| | | |
|---|---|---|
| ១– | ស្លា | ១០០ ដៃ |
| ២– | ម្លូ | ២០០ ក្របក |
| ៣– | ថ្នាំ | ២៨ ដុំ |

៤– ស្លាព្រា ២៨ ដុំ

៥– ទៀន ១ –

៦– ស្រា ៤ សឹក

របស់អំបាលនេះ ញែកដាក់រងម្ភតោក ១ គូ

៧– ចេកទុំ ២ តោក

៨– អន្សម ២ –

៩– នំគម ២ –

១០– នំបង់ខ្ញញ់ ២ –

១១– នំកន្ត្រំ ២ –

១២– នំក្រូច ២ –

ព្រមទាំងបន្លែ ៣ មុខ រួមប្រមាណជា ១ កញ្ជ្រែង នឹង អង្ករ ត្រី-មាន់-ទា ទៀតតាមសមគួរ ។

ឯឈ្មោះរបស់ នឹងចំនួនរបស់ ជាគ្រឿងបណ្ដាការ សម្រាប់ដណ្ដឹង ដែលរៀបរាប់មកខាងលើនេះបានកត់យក

តាមរបៀបដែលមានក្នុងសៀវភៅទម្រង់ការបុរាណ ១ យ៉ាង ដែលថា ព្រះជ័យចេស្ដាភិមាតស្សូវទ្រង់តែងទុក សុំឲ្យប្រាប់ថា បែបនេះជារបៀបបុរាណសុទ្ធ លុះកន្លងមកដល់វេលានេះ របៀបនោះបានប្រែប្រួលទៅតាមកាលៈទេសៈនិយម ដូចយ៉ាងគ្រឿងផ្លែឈើ របស់ចាស់មានតែផ្លែចេក ១ មុខ សព្វថ្ងៃស្រុកខ្លះដែលសម្បូណ៌ផ្លែឈើ គេប្រើផ្លែឈើផ្សេងៗ ច្រើនមុខជាងនោះ ដូចយ៉ាងផ្លែក្រូច-មង្ឃុតល្មុត-ម្នាស់ ។ល។ (តាមរដូវដែលឈើណាផ្លែ ក៏ប្រើផ្លែឈើនោះ) នឹងត្រូវរៀបរបស់សម្រាប់បញ្ចាំចិត្ត ជាគ្រឿងមាស-ពេជ្រ ដូចយ៉ាងខ្សែខ្លួន-ខ្សែក កង ទំហ៊ូ យ៉ាងណានិមួយ នឹងសំពត់ស្លៀក ១ អាវព្រែ ១ ក្រមាព្រែ ១ (ជូនកាលមានឆត្រ ១ ផង) ។

កាលរៀបរួចហើយ ត្រូវប្រគល់ឲ្យអ្នកជំនូវ, អ្នកមហានិងអ្នកជំនួយខ្លះទៀត នាំទៅកាន់ត្រកូលខាងស្រី នឹងត្រូវតាក់

តែនកូនប្រុសដែលវាសនាមុំខ្លួនឲ្យទៅជាមួយនោះផង កាល
ទៅដល់ភូមិនោះ អ្នកផ្លូវត្រូវប្រាប់ឲ្យកូនប្រុសទៅសំណាក់
នៅផ្ទះអ្នកណានិមួយ មួយអន្លើសិន រង់ចាំគេយកខ្លួនសឹម
ទៀនទៅ ។ ចំណែកឯអ្នកផ្លូវមេបាត្រូវនាំបណ្ដាការ
ទៀនទៅលើផ្ទះខាងស្រី ក្នុងវេលានោះនឹងឃើញពួកមេបា
ប្រុស-ស្រីអង្គុយចាំត្រៀបត្រា ។ ខណៈនោះអ្នកផ្លូវត្រូវជំរាប
ថា " សូមជំរាបអស់ លោកមេបាប្រុស-ស្រី សូមជ្រាប
ថ្បិតសាមីដើមការបានពឹងពររកខ្ញុំជាអ្នកផ្លូវ ឲ្យមកសូម
ដណ្ដឹងកូនស្រីរបស់លោកមេបា ពីរជើងរួចមកហើយ
ជួបលោកមេបាជ្រាបស្រាប់តែគ្រាក្រោយនោះលោក
មានប្រសាសន៍ថា ខ្ញុំជាអ្នកផ្លូវនេះជាស្រីស្រដីការ
អ្វីពុំជាប់ស្រេច នឹងទទួលការបង្គាប់បញ្ជារពីលោក
មេបាក្រែងពុំបាន ទើបលោកឲ្យខ្ញុំទៅជំរាបលោក

ដើមការ ឲ្យពឹងរកប្រុសដែលមានសក្តិបញ្ញាមក
និយាយការនឹងលោក ឥឡូវអ្នកសាមីដើមការបាន
ពឹងរកបុរសដែលមានគុណសម្បត្តិ ដូចដែលលោក
មេបាបានបង្គាប់ទៅគឺអ្នកទាំង ៣ នេះ ឲ្យខ្ញុំនាំមក
ប្រណិប័តន៍ជូនលោកមេបា ដើម្បីនិយាយមង្គលគ្រប់
ជំពូកតទៅ ៖ ក្នុងវារៈជាគំរប់ ៣ ជើងនេះសូម
ឲ្យលោកមេបាបញ្ញត្តគ្រប់ជំពូក មកលើអ្នកមហា
អំបាលនេះដែលជាអ្នកតំណាងសាមីដើមការ នឹង
បានប្រតិប័តន៍តាមគួរនឹងការ ។

*លំដាប់នោះអ្នកមហាគ្រូប្តីនស្មើរអំពីមុខតំណែងរបស់*
ខ្លួនថា៖ សូមទានក្រាបប្រណិប័តន៍ អស់លោកមេបា
ត្រកូលរៀមច្បងធំ.តូច សូមទានជ្រាប ។

ដ្បិតអ្នកសាមីដើមការបានពឹងពាក់ខ្ញុំប្របាទឲ្យមកធ្វើជាមហា សូមជំរាបមង្គលការទាំងពួងនឹងលោកមេបា តាមច្បាប់រណ្ដាប់ស្រុក ដូច្នេះ សូមលោកមេត្តាពិតពិលរមិលមើលខ្ញុំប្របាទ ជាល្មមធ្វើជាមហាបានឬយ៉ាងណា ? បើលោកមេត្តាអនុក្ូលចូលចិត្តតាំងឲ្យខ្ញុំប្របាទធ្វើជាមហាហើយ ខ្ញុំប្របាទសុំពាក់អាវផាយ ស្រាយមាត់បង់តម្រង់ពេង នឹងអុជទៀនទាំងគូ សូមក្រាបប្រណិប័តន៍និយាយមង្គលការតទៅតាមការ ។

*ពួកមេបាត្រូវអនុម័តថា* : បើយើងអនុញ្ញាតឲ្យអ្នកធ្វើជាមហាពេញយសសក្តិចុះ ។

*ទំនៀមអ្នកមហាទាំង ៣ នាក់ ត្រូវពាក់អាវពណ៌ក្រហម*

សុទ្ធ ឬលាយដោយពណ៌ក្រហម អាវដែលធ្លាប់ប្រើមកហើយ
គឺអាវល្បើកការក្តាមាសប្រាក់ អាវសារបាប់ផាដើម អ្នកដែ
ទទួលមិនមានអាវតំបាលនេះ សូមទ្រឹនប្រើអាវព្រៃ ឬ អាវ
ដែលពណ៌ក្រហមក៏បានដូចគ្នា, អ្នកមហាធំ ត្រូវមានអាវផាយ
ពណ៌ក្រហមពាក់ពីលើទៀតផង ។ ចំណែកឯសំពត់ស្បៀ
ក៏ប្រើសំពត់ពណ៌ក្រហមសុទ្ធ ឬលាយដោយពណ៌ក្រហមដូច
គ្នា សំពត់ដែលគេធ្លាប់ប្រើមកហើយ គឺសំពត់ល្បើក សំពត់
ផាមួង សំពត់ហូល សំពត់សារបាប់ផាដើម ។ ដើម្បី
ត្រៀងសំគាល់យសស័ក្តិ ដែលធំតូចជាងគ្នា ដោយលំដាប់
នៃអ្នកមហាទាំង ៣ នាក់នោះ អ្នកមហាទី ១ ត្រូវប្រើសំពត់
អាវពណ៌ក្រហមឆ្អិត, អ្នកមហាទី ២ ត្រូវប្រើពណ៌ក្រហមភ្លាវ
បន្តិចចុះមក, អ្នកមហាទី ៣ ត្រូវប្រើពណ៌ក្រហមទៀន ។
សុំឱ្យដ្រាយថា សំពត់ពណ៌ក្រហមជាសំពត់លេខ ១ ជាពណ៌
មង្គល លោកបញ្ញត្តឲ្យប្រើក្នុងកិច្ចមង្គលការទាំងពួង សម្រាប់

អ្នកមហា នឹងសាមីខ្លួនកូនប្រុស-ស្រី ត្រូវប្រើពាណ៌នេះជា
ដរាប · ចំណែកអ្នកឯទៀតនោះ មិនជាប្រមាណ តែពួក
អ្នកដែលកាន់សណ្ដាប់នេះតិចរ៉ុង គេក៏មិនស្លៀកពាក់ពាណ៌
ក្រហមនៅក្នុងពិធីមង្គលការដែរ ។ អ្នកមហាទី ២ មាន
គ្រឿងប្រដាប់សម្រាប់ខ្លួនកាន់គឺ ថង់ ១ មានស្រា១ដប ពែង
១ គូ គឺដាក់លើថង់នោះ និងទៀន ១ គូ បិទនៅមាត់ថង់,អ្នក
មហាទី ៣ មានថង់គ្រឿងស្លា ១ អកកំបោរគ្រឿងស្លានោះគេ
ប្រើអកសំរិទ្ធិ បើគ្មានអកសំរិទ្ធិ៍ គេប្រើអកប្រាក់ គ្រឿងឯ
ទៀត គេប្រើគ្រឿងប្រាក់ មានកន្សែងបញ្ចូពណ៌ ឬកន្សែង
ប្រម៉ុច ១ ក្រាលនៅទ្រនាប់គ្រឿងស្លានោះ ។ កាលមេបា
អនុញ្ញាតឲ្យតែងពេញយសស័ក្តិហើយអ្នកមហាធំ ត្រូវពាក់អាវ
ផាយក្រហមឡើង (តែស្រុកស្រែចំការ ដែលគ្មានអាវផាយ
គេមិនបាច់ពាក់ក៏បានដែរ) អ្នកមហាទី ២ ត្រូវអុជទៀននៅ
ថង់នោះឡើង ហើយផ្គងកាន់ថង់នោះ ដោយដៃទាំងពីរ ទាំង

ស្មុកមហាទី ៣ ក៏ត្រូវលើកវេនស្លាដូចកាន់ឡើងដូចគ្នានោះ , ស្មុកមហាទី ១ ប្រណម្យដៃឡើងហើយ បន្ទន់ខ្លួនបន្តិចជាកិរិយាគោរពពួកមេបា ហើយនិយាយថា សូមទានសូមក្រាបប្រណិប័តន៍អស់លោកមេបាសូមទានជ្រាប ។ ដ្បិតសាមីខ្លួនដើមការបានពឹងពរអកខ្ញុំប្របាទទាំង ៣ នាក់ឲ្យមកបងស្ពានមេត្រីដណ្ដឹងកូនស្រីលោកមេបាឈ្មោះនាង..នោះ ឲ្យជាភរិយាឈ្មោះ(១)នាយ ... នោះជាបុត្ររបស់អ្នកសាមីដើមការ បើលោកមេត្តាឲ្យទាន នឹងបានលើកស្លាបញ្ជាប់ពាក្យ ព្រមដោយភស្តុភារបណ្ដាការជូនពិសានឹងសូមប្រណិប័តន៍ ជូនទ្រព្យបញ្ចាំចិត្តទុកជាសំគាល់តទៅ ។

---

១— បើកូនប្រុសនោះ មានបណ្ដាសក្តិដូចម្ដេចត្រូវពោលចេញតំណែងនឹងយសសក្តិនោះ ។

*ពួកមេបាត្រូវឆ្លើយតបតាមសមគួរថា :* ការដែលអ្នកសាមីដើមការបានពឹងពររកអ្នកនូវហៅមហា ឲ្យមកសូមដណ្ដឹងកូនស្រីយើងជាគំរប់ ៣ ដងហើយនោះ យើងក៏រសៀលចិត្តណាស់ទៅដែរហើយ តែយើងមិនទាន់អស់អញ្ជល់គេញក្នុងចិត្តដោយហេតុថាយើងរាល់គ្នាជាមេបា ពុំទាន់ដែលបានឃើញរូបឆោមកូនប្រុសរបស់អ្នកមហា មិនដឹងជាមានរាងកាយវិកលវិការជរាទុព៌លភាពយ៉ាងណា ឬល្អជាទេ នោះយើងពុំបានឃើញ ពុំបានដឹង ។

*អ្នកមហាគប្បីជំរាបតាមពិតថា* សូមទានសូមក្រាបប្រណិប័តន៍អស់លោកមេបា សូមទានជ្រាប ។

ឯកូនប្រុសខ្ញុំប្របាទនោះមានរូបឆោមជាមធ្យម

បុរស គឺគមានវិកលវិការអវយវៈឯណានិមួយ ដែល
មិនគួរដល់ការងារសម្រាប់ខ្លួននោះទេ ។

*ពួកមេបាត្រូវថា* : ដែលអ្នកមហានិយាយមកនេ
មាត់ទទេដូច្នេះ នឹងយកជាបន្ទាល់ពុំបាន ត្រូវឲ្យ
អ្នកមហានាំខ្លួនកូនប្រុសមក ឲ្យយើងជាមេបារាល់គ្នា
ពិនិត្យមើលក្នុងកាលឥឡូវនេះ ។

*អ្នកមហាត្រូវប្រាប់អ្នកផ្ទូវ ឲ្យទៅនាំយកកូនប្រុសមក ។*
*កាលកូនប្រុសមកដល់ហើយ អ្នកមហាត្រូវជំរាបជូនខ្លួនកូន*
ប្រុសថា សូមទាន, សូមក្រាបប្រណិប័តន៍ជូនខ្លួនកូន
ប្រុស សូមលោកមេបាពិនិត្យមើលរូបឆោមចុះ ។

*ពួកមេបាត្រូវបង្គាប់ឲ្យកូនប្រុសនោះ ដោះអាវចេញ*
*ហើយពិនិត្យមើលរាងកាយសព្វគ្រប់ទៅ កាលពិនិត្យរួចហើយ*
*ទើបគេតបទៅអ្នកមហាវិញថា* : កូនប្រុសអ្នកមហានោះ

មានរូបឆោមគ្រាន់បើហើយ តែយើងនៅមានចិត្ត ពិចិលឆ្ងល់សង្កាថា ក្រែងកូនប្រុសអ្នកឯង ជាអ្នកលេង-ប្រមឹកផឹកស្រវឹង ជក់អាភៀនញៀនកញ្ឆា ឬប្រព្រឹត្តភាល់លេងល្បែងដើរស៊ីសង រហូតដល់ទៅមានជំពាក់បំណុលគេដ៏លើសលុប ឬមានស្រីសង្សារកំណាន់ចិត្តហើយ តែមាតាបិតានាំបង្វែងមកដណ្តឹងកូនយើង អម្បាលនេះជាដើមជាកិច្ច ដែលយើងត្រូវពិនិត្យដែរ ។

*អ្នកមហាត្រូវម្ដេជ្រាននឹង ទទួលធានាលើខ្លួនចំពោះមុខកូនប្រុសថា ៖* កូនប្រុសខ្ញុំប្របាទជាអ្នកប្រព្រឹត្តសុចរិតល្អត្រង់ត្រឹមត្រូវជួបអ្នកស្រុកទាំងពួង មិនមានប្រព្រឹត្តបទអាក្រក់ ទាក់ទាមដោយបទអាក្រក់ទាំងប៉ុន្មាន

ដូចលោកចោទមកអម្បាញមិញនោះទេ ខ្ញុំប្របាទ សូមធានាលើខ្លួន សូមឲ្យលោកស៊ើបសួរមើលចុះ បើមិនពិតដូចខ្ញុំប្របាទថា ខ្ញុំប្របាទសូមទទួលទោស ដោយឲ្យលោកផ្ដាច់ចេញ ហើយឲ្យអូសយកភស្តុភារបណ្ដាការ ដែលជូនបញ្ជាប់ពាក្យបញ្ជុំចិត្តទាំងអស់ចុះ ។

*អ្នកមហាត្រូវទទួលចុះសម្រេចថា :* អើបើអ្នកមហាទទួលធានាលើខ្លួនដូច្នេះ យើងក៏ព្រមល្មមឲ្យហើយ តែថាតាំងអំពីនេះទៅ ត្រូវអ្នកមហាប្រាប់កូនប្រុសឲ្យស្គាល់នឹងរាប់អាន យើងរាល់គ្នាមេបាអម្បាលនេះ គឺឈ្មោះជាឪពុកធំ ឈ្មោះនេះជាម្ដាយធំ ឈ្មោះនេះជាមា ឈ្មោះនេះជាម្ដាយមីង ។ល។

អ្នកមហាត្រូវទទួលថា ៖ ខ្ញុំប្របាទនឹងរៀនប្រដៅកូនប្រុសឲ្យស្គាល់ នឹងគោរពរាប់អានអស់លោកមេបាត្រកូលរៀមច្បង ។ ប៉ុណ្ណេះហើយ អ្នកមហាត្រូវលើកគ្រឿនស្លាបញ្ញាប់ពាក្យ ជូនទៅមេបាស្រីពិសា ពួកមេបាគប្បីរៀកម្ហូ ពិសាម្តង ២ លន្លឹកដូចមុន ១ ។

លំដាប់នោះ, អ្នកមហាត្រូវជំរាបមេបាថា ៖ សូមអស់លោកមេបាមេត្តាពិតពិលរមិលមើលនូវគ្រឿងភស្តុភារបណ្ណាការអម្បាលនេះ បើឃើញខ្វះខាតត្រង់មុខណានឹងបានបែមជូនទាល់តែគ្រប់គ្រាន់ ។ ពួកមេបាត្រូវថាល្មមគួរសមហើយ ។ ហើយត្រូវព្រាប់ស្មៀនម្នាក់ ឲ្យមកកត់របស់ទាំងអម្បាលនោះទុកជាចំណាំតទៅ ក្រែងកើតហេតុទៅថ្ងៃក្រោយនឹងបានជាបន្ទាល់ ។ ប៉ុណ្ណោះឈ្មោះចាំ

ស្រេចការក្នុងរឿងដណ្ដឹងហើយ ។

ក្នុងឱកាសដែលស៊ីស្លាកញ្ចប់ពាក្យហើយនេះ តាមទំនៀមបុរាណ អ្នកមហាត្រូវជំពាបសូមឲ្យមេបា បន្ទាប់ពីរៀនធ្វើផ្ទះការ មេបាត្រូវបង្គាប់ឲ្យធ្វើផ្ទះ ១ ខ្នង ៣ ល្វែង មានហប់មុខហប់ក្រោយ ។ គ្រឿងផ្ទះនោះយកឈើអ្វីប្រវែងទទឹង បណ្ដោយប៉ុន្មានម៉ែត្រ កំពស់ប៉ុន្មានម៉ែត្រ ប្រក់ស្លឹកឬប្រក់ស្បឿង ជញ្ជាំងស្លឹកឬជញ្ជាំងក្ដារ ក្រាលរនាបឬក្រាលក្ដារ ត្រូវបង្គាប់ឲ្យសព្វគ្រប់ដែរ តែមុននេះ ត្រូវមេបាពិតពិលមើលមើលដល់ធនធាន និងវង្សត្រកូលទាំងសងខាង និងត្រូវព្រមព្រៀងមួយអន្លើ ដោយមាតាបិតាឬអ្នកណាញាតិទាល់ស្គាល់ ហើយបង្គាប់ឲ្យជាអនុរូបទៅតាមភាពនោះឲ្យល្មមតែធ្វើកើត ហើយត្រូវកំណត់ទុកពេលឲ្យធ្វើក្នុងរវាងពី ៦ ខែ ទៅដល់មួយឆ្នាំ ។ តែសម័យនេះ ពួកអ្នកក្រុងគេមិន

បង្គាប់ឲ្យធ្វើផ្ទះទេ គេបង្គាប់យកជាប្រាក់ជំនួសក៏មាន គេមិនបង្គាប់ក៏មាន ។ ចំណែកឯអ្នកស្រុកក្រៅ នៅកាន់ទំនៀមបង្គាប់ឲ្យធ្វើផ្ទះនៅឡើយជាច្រើន ។

ក្នុងឱកាសដែលដណ្តឹងជាគំរប់ ៣ ឆ្នាំនោះ ពួកមេបាបានសួរបញ្ជាក់ពីគំនិតមារយាទរបស់កូនប្រុសសព្វគ្រប់ អ្នកមហាបានជំរាបថា មានគំនិតមារយាទល្អ សូមឲ្យស៊ើបសួរមើលចុះ បើមិនពិតដូចពាក្យជំរាប សូមឲ្យផ្តាច់ចេញចុះ តែម្ល៉ឹងហើយ ក៏ពួកមេបានៅមិនទាន់អស់ចិត្ត ទើបមានទំនៀមថា ពីត្រឹមវេលាដែលដណ្តឹងគ្រប់ ៣ ឆ្នាំហើយ ត្រូវឲ្យកូនប្រុសទៅបំរើម្តាយក្មេកឪពុកក្មេក ដរាបដល់ពេលរៀបការ ។ ការដែលឲ្យកូនប្រសា ទៅនៅបំរើដូច្នេះ ក៏ដើម្បីនឹងពិនិត្យមើលគំនិតមារយាទនោះឯង ។ ក្នុងរវាងដែលកូនប្រសាទៅនៅបំរើនោះ មានផ្តាច់ជាច្រើនណាស់ហើយ ដោយ

ហេតុកូនប្រុសានោះ ទៅសំដែងកិរិយាមារយាទអាក្រក់ឲ្យគេឃើញ ។

តែការដែលទៅនៅបំរើ មិនមែនសុទ្ធតែត្រូវទៅនៅទាំងអស់គ្នាដោយខានមិនបាននោះទេ ស្រេចហើយតែម្ដាយក្មេកឪពុកក្មេក គេត្រូវការឲ្យទៅនៅបំរើផង ទើបទៅនៅបំរើបាន អ្នកខ្លះគេមិនចូលចិត្តឲ្យកូនប្រសា ដែលមិនទាន់ស៊ប់ដូច្នេះមកនៅបំរើក៏មានដែរ ។ គេមិនត្រូវការឲ្យមកនៅបំរើក្ដី ឬសាមីខ្លួនកូនប្រសានោះ ជាអ្នកទីទ័លក្រ គ្មានអ្នកកាន់កាប់ការក្នុងផ្ទះជំនួសខ្លួនក្ដី កូនប្រសានោះជាអ្នករាជការក្ដី អំពាលនេះសម្បីមិនទៅនៅបំរើក៏បាន ។

## ៥– របៀបជូនពេលា

អ្នកដែលត្រូវធ្វើផ្ទះក្ដី អ្នកដែលមិនត្រូវធ្វើផ្ទះក្ដី កាលដល់ឱកាសណាមួយដ៏សមគួរហើយ ត្រូវជូនពេលា គឺកំណត់ថ្ងៃ ខែ ដែលនឹងរៀបមង្គលការឲ្យទៅខាងស្រីជ្រាប

សូមអនុញ្ញាតរៀបការកូនតាមកំណត់នោះ តែអ្នកដែលត្រូវធ្វើផ្ទះនោះ ត្រូវជូនកូនទៅណាដែលធ្វើផ្ទះរួចហើយ គឺត្រូវឲ្យហោរឬអាចារ្យគន់គូរមើលឫក្សថ្ងៃ ខែ ដែលល្អគួរនឹងរៀបមង្គលការបាន ។ តាមទំនៀម គេត្រូវវៀរដែលលេខសេសគូ បាននឹងខែលេខ ១, ៣, ៥, ៧, ៩, ១១ ។ ត្រូវធ្វើកូនខែដែលលេខគត់គូ គឺខែលេខ ២;៤,៦,៨ ១០ ១២ តែបើកូនរដូវភិក្ខុសង្ឃចូលវស្សា គឺរដូវវស្សាពី ១ រោច ខែអាសាឍទៅដល់ ១៥ កើតខែអស្សុជ សូម្បីខែជាលេខគត់គូ ក៏ត្រូវវៀរដែរ ។ កាលគន់គូរទៅហើយ ត្រូវលើថ្ងៃខែណាក៏ត្រូវកត់ថ្ងៃខែនោះ ចុះក្នុងផែនក្រដាសមួយ ហើយត្រូវរៀបកស្តុភារជាកំដរដៃតាមទំនៀម គឺ :

១– ស្លា ១០០

២– ម្លូ ១០០

៣– ចេកទំ ២ ស្និត

៥ - រង្គស្វា ដាក់គ្រឿងស្វាសព្វគ្រប់

រួចហើយត្រូវប្រគល់ឲ្យអ្នកផ្សំ ព្រមទាំងក្រដាសកំណត់ពេលា ឲ្យនាំយកទៅជូនមេបាខាងស្រី ៗ កាលបានទទួលហើយ បើមិនមានធុរៈជាទម្ងន់ទេ ត្រូវអនុញ្ញាតឲ្យគេ ៗ កាលបើបានអនុញ្ញាតព្រមព្រៀងគ្នាហើយ អ្នកផ្សំត្រូវជំរាប

សូមឲ្យមេបាបង្ហាប់គ្រឿងភស្តុភារបណ្ណាការសព្វសរពើដែលត្រូវជូន នឹងត្រូវប្រើប្រាស់ក្នុងឱកាសធ្វើមង្គលការ ៗ មេបាត្រូវកត់ចំនួនភស្តុភារបណ្ណាការទាំងនោះ ដោយជំពូក ៗ តាមសមគួរហើយ ត្រូវប្រគល់ឲ្យអ្នកផ្សំ យកទៅជូនអ្នកសាមីដើមការ ៗ

## ៦ - របៀបបង្ហាប់

ឯភស្តុភារបណ្ណាការនោះ តាមទំនៀមបុរាណដែលមានក្នុងសៀវភៅទម្រង់ការមួយយ៉ាង ដែលថា ព្រះជ័យចេស្តាភាមាត់ស្បូរ ទ្រង់តែងតាំងទុកនោះ ថាត្រូវបង្ហាប់ដូច្នេះ :

# ក) គ្រឿងបណ្ដាការការធំ

១– ស្លា ១.០០០ ដៃ

២– ម្លូ ១.០០០ គ្រាប់

៣– ថ្នាំ ៥ នាឡិ

៤– ស្លាថ្នា ១ ជាលកន្ទុះ

៥– កំពោរ ២ ត្រម្ម

៦– អង្ករខ្សាយ ២ ហាំង

៧– អង្ករដំណើប ១ ហាំង

៨– ត្រីស្រស់ ៧ ស្នែង (កន្ទ១ស្នែងត្រី៣០រាយ)

៩– ត្រីងៀត ១៥ រាយ

១០– ត្រីឆ្អើរ ១៥ –

១១– មាន់ ៣០ –

១២– ទា ១៥ –

១៣– ប្រហុក ៥ នាឡិ

១៤- អំបិល ១ ពាងតូច

១៥- ស្រា ៤ ក្អម (ក្អមគោកគ្រួស)

១៦- ស្រាពពុះ ១ ក្អម

១៧- បង្វែ ១០ មុខ

១៨- ផ្លែឈើ ៣០ មុខ (ក្នុង១មុខ ១ស្លឹក ៥ ផ្លិន)

តែតម្រាខ្លះថា ក្នុង ១ មុខ ៣ ស្លឹក តាមចំនួននេះ

រួមទាំងនំផង ។

## ចំនួនគ្រឿងបណ្ណាការ

ចំនួនគ្រឿងបណ្ណាការឯទៀត ដែលនឹងពោលតទៅនេះ គប្បីជ្រាបថា ជារបៀបដែលគេកំណត់ប្រើក្នុងសម័យព្រេងនាយឯណោះ សព្វថ្ងៃអ្នកនគរមិនបានជាកាន់យកតាមកំណត់នេះទាំងអស់ទេ យកខ្លះ មិនយកខ្លះ ព្រោះកាលៈទេសៈប្រែប្រួលទៅ មានរបៀបរបស់ថ្មីផ្សេងៗ កើតឡើង គេក៏

ប្រើរបស់ថ្មីជាជំនួសរបស់ចាស់នោះៗក៏មាន គេលះបោលតែម្តង ដោយមិនមានប្រើរបស់ជំនួសក៏មាន ដូចជាយ៉ាន់អំបិលប្រហុកជាដើម គេឈប់បង្គាប់ គេបង្គាប់ទឹកត្រីជំនួសក៏មានមិនបង្គាប់សោះក៏មាន ត្រីស្រស់-ត្រីងៀត-ត្រីឆ្អើរ គេក៏ឈប់បង្គាប់ដែរ គេបង្គាប់សាច់ជ្រូកជំនួស ក្នុងការមួយ ប្រើសាច់ជ្រូកទម្ងន់តាំងពីមួយហាបឡើងទៅរហូតដល់ពីរហាប តាមការតូច ការធំ ការដែលធំមែនទែន ជួនកាលមានសាច់គោៗមួយទៀតផង របស់ក្រៅពីនេះ គេអាចបន្ថយឲ្យតិចចុះក៏បាននឹងបន្ថែមឡើងលើសកំណត់នោះក៏បាន តាមរូបការតូចធំៗ

## ១)- គ្រឿងបណ្ដាការស្លាកំណត់

( លោកបាត្រូវឲ្យបង្គាប់ឲ្យថយចុះពីបណ្ដាការការធំពាក់កណ្ដាល) គឺ :

១- ស្លា ៥០០ ដៃ

២- ម្លូ ៥០០ ត្របក

៣– ថ្នាំ ២ នាឡិកន្លះ

៤– ស្លាជ្លា ៨ ដម្លឹង

៥– កំបោរ ១ តុម្ព

៦– អង្ករខ្សាយ ១ បាំង

៧– អង្ករដំណើប ១ តៅ

៨– ត្រីស្រស់ ៣ ស្លឹងនឹង ១ ពុន

៩– ត្រីងៀត ៧ ភាយ

១០– ត្រីឆ្អើរ ៧ –

១១– មាន់ ១៥ –

១២– ទា ១៥ –

១៣– ប្រហុក ២ នាឡិកន្លះ

១៤– អំបិល កន្លះពាង

១៥– ស្រា ២ ក្អម (ទុំទិន)

១៦– ស្រាពពុះ ១ គៀន(ប្រមាណកន្លះក្អម)

១៧– បន្លែ ៥ មុខ

១៨– ផ្លែឈើ ១៥ មុខ (ចំនួននេះរួម

ទាំងនំនឹងផ្លែឈើ)

គ)– គ្រឿងបណ្ណាការស្លាប់រង ត្រូវបង្គាប់ជូនព្រះ :

១– ស្លា ២០៥ ដៃ

២– ម្លូ ២០៥ ត្របក

៣– ថ្នាំ ១ នាឡិ

៤– ស្លាម្លូ ៨ ដម្លឹង

៥– កំបោរ ១ ក្អម

៦– អង្ករខ្សាយ ១ តៅ

៧– អង្ករដំណើប ១ កន្តាំង

៨– ត្រីស្រស់ ១ ពុន

៩– ត្រីងៀត ៥ ភាយ

១០– ត្រីឆ្អើរ ៥ –

១១– មាន់ ៧ ភាយ

១២– ទា ៣ –

១៣– ប្រហុក ១ នាឡិ

១៤– អំបិល ១ សៀន

១៥– ស្រាចំណាយ ១ ក្អម

១៦– ស្រាពពុះ ១ ក្អម

ឃ)– គ្រឿងបណ្ដាការស្លាកស្នែង ត្រូវបង្គាប់ដូច្នេះ:

១– ស្លា ១០៥ ដៃ

២– ម្លូ ១០៥ ត្របក

៣– ថ្នាំ ៦ ដបូង

៤– ស្លាផ្កា ៥ ដុំ

៥– កំបោរ កន្លះត្រឡ

៦– អង្កខ្សាយ ១ កញ្ជើ

៧– អង្ករដំណើប ១ កន្ដាំង

៨- ផ្លែឈើកំរៀម ៥ គោក (ក្នុង ១ គោក ២ ម្ហូន ៥ ដំបរ)

៩- ស្រាចំណាយ ២ ឰជ

១០- ស្រាពពុះ ១ ស៊ឹក

១១- ត្រីស្រស់ ១ ពុន

១២- មាន់ ៤ រាយ

១៣- ទា ២ -

១៤- បង្គៃ ១ កញ្ជ្រែង (រួម ៥ មុខ)

១៥- បាយសម្ល ៥ ហិស

បាយសម្ល ៥ ហិសនេះ សម្រាប់សែនព្រេនដូនតា ។ ហើយជូនឲ្យមេបាពិសារ តែរបៀបសែនព្រេនដូនតាក្នុងសម័យនេះ ឃើញច្រើនតែគេបង្គាប់ឲ្យមាន ចំអាប ២ ហិស បង្អែម ២ ហិស មាន់ស្ងោរមួយគូ ទាស្ងោរមួយគូ សាច់ជ្រូក១ភ្លៅ ។

## ង)– គ្រឿងបណ្ដាការស្លាដក់ ត្រូវបង្គាប់ដូច្នេះ :

១– ស្លា ៥ ដៃ

២– ម្លូ ៥ ត្របក

៣– ថ្នាំ ៣ ដុំ

៤– ស្លាផ្អុំ ២ –

៥– ស្រា ១ កំប៉ុក

៦– ទៀន ១ គូ

៧– ប្រាក់ ១ ស៊ឹង (តម្រាខ្លះថា ប្រាក់ ១ បាទ)

គ្រឿងស្លាដក់នេះឲ្យវេចនឹងកន្សែងបញ្ចពណ៌ ដំកល់លើរនាមួយ ។

## ប)– រណ្ដាប់ស្លាព្រះពរ ដូច្នេះ

១– ស្លា ៣ ដៃ

២– ម្លូ ៥ ត្របក

៣- ឃ្មុំ ៣ ដុំ

៤- ស្លាថ្លា ២ -

៥- ទៀន ១ គូ

៦- ផ្កា ៣ ទង

ឆ)- រណ្ដាប់ស្លាជ័យ ដូចជា៖ :

១- ស្លា ១០០ (តម្រាខ្លះថាស្លា៥ដៃ)

២- ម្លូ ១០០ ត្របក

៣- ឃ្មុំ ៥ ដុំ

៤- ស្លាថ្លា ៣ -

៥- ទៀន ១ គូ

៦- ប្រាក់ ១ បាទ (តម្រាខ្លះថាប្រាក់ ៣ ស្លឹង)

ជ - រណ្ដាប់ប្រសព្វមុខការកំ ដូចជា៖

១- ស្លា ៣ ដៃ

២ - ម្ជូ ៥ ត្របក

៣ - ថ្នាំ ៣ ដុំ

៤ - ស្លាធ្វើ ៣ -

៥ - ទៀន ១ គូ

៦ - ប្រាក់ ៥ បាទ (តម្រាខ្វះហិប្រាក់ ៥ ស៊ីង)

ឈ)- វណ្ណាប់ប្រសព្វមុខការកំណត់ដូច្នេះ:

១ - ស្លា ២ ដៃ

២ - ម្ជូ ៤ ត្របក

៣ - ថ្នាំ ២ ដុំ

៤ - ស្លាធ្វើ ២ -

៥ - ទៀន ១ គូ

៦ - ប្រាក់ ២ បាទ ២ ស៊ីង (តម្រាខ្វះ ហិ ៣ ស៊ីង)

## ញ)- វណ្ណាប់ប្រសព្វមុខគោះបង់រង ដូច្នេះ

១- ស្លា ៣ ដៃ

២- ម្លូ ៣ ត្របក

៣- ថ្នាំ ១ ដុំ

៤- ស្លាផ្កា ១ -

៥- ទៀន ១ គូ

៦- ប្រាក់ ១ស្លឹង

## ដ)- បំនួនប្រាក់ខាន់ស្លា

ឯប្រាក់ខាន់ស្លា លោកកំណត់ទុកឲ្យមេបាកាត់យក តាមបណ្ដាស័ក្តិរបស់វង្សត្រកូលខាងប្រុស លោកចែកត្រកូលជា ៤ គឺ ត្រកូលរាជស័ក្តិ ១, ត្រកូលឧត្តមស័ក្តិ ១, ត្រកូលបុរាណស័ក្តិ ១, ត្រកូលភព្វស័ក្តិ ១, ។ ត្រកូលដែលជាប់ដំណាសន្តតិវង្ស ដោយខត្តិយត្រកូល ហៅជាត្រកូលរាជស័ក្តិ

លោកឲ្យយកជាតិស័ក្តិទឹកមាស ៩ មកកាត់ជាប្រាក់ ៩០ ដម្លឹង ៣ បាទ ៣ ស្លឹង ជាចតុគុណ ត្រូវនឹងប្រាក់សព្វថ្ងៃនេះជា ១០៥'៥០ ៛ ត្រកូលមន្ត្រីមានបណ្តាស័ក្តិតាំងពី ១០ ហ៊ូពាន់ ចុះមកដល់ ៦ ហ៊ូពាន់ ហៅជាត្រកូលឧត្តមស័ក្តិ លោកឲ្យយកជាតិទឹកមាស ៦ មកកាត់ជាប្រាក់ ៦០ ដម្លឹង ២ បាទ ២ ស្លឹង ជាត្រីគុណ ត្រូវនឹងប្រាក់សព្វថ្ងៃនេះជា ៩១'៩០ ៛ ត្រកូលដែលមានបណ្តាស័ក្តិជាន់ទាបតាំងពី ៥ ហ៊ូពាន់ចុះមកដល់ទីស្នង ក្រឡាពាស មេស្រុក អម្បាលនេះហៅជាត្រកូលបុរាណស័ក្តិ លោកឲ្យយកជាតិទឹកមាស ៣ មកកាត់ជាប្រាក់ ៣០ ដម្លឹង ១ បាទ ២ ស្លឹង ជាទ្វេគុណ ត្រូវនឹងប្រាក់សព្វថ្ងៃនេះជា ៤១'៤០ ៛ ត្រកូលរាស្ត្រអ្នកស្រុកធម្មតា ហៅជាត្រកូលភព្វស័ក្តិ លោកឲ្យយកជាតិទឹកមាស ១ មកកាត់ជាប្រាក់ ១២ ដម្លឹង ២ ស្លឹង ត្រូវនឹងប្រាក់សព្វថ្ងៃនេះជា ១៩'៧០ ៛

បើគ្រាន់តែកាត់បង្រួបច្បាប់មិនបានយកជាច់ទេ ត្រកូលបុរាណស័ក្តិ កូនច្បងនឹងកូនពៅ លោកឲ្យកាត់ ១៤ ដម្លឹង ២បាទ១ ស្លឹងស្មើគ្នា ត្រូវនឹងប្រាក់សព្វថ្ងៃនេះជា ២០៍៣០ ។ កូនបន្ទាប់ពីច្បងចុះទៅឲ្យកាត់ ៩ ដម្លឹង ៣ បាទ ២ ស្លឹង ត្រូវនឹងប្រាក់យើងសព្វថ្ងៃនេះជា ១៥៍៨០ ។ ត្រកូលតពូស័ក្តិឲ្យកាត់ ៧ ដម្លឹង ១ បាទ ១ ស្លឹង ត្រូវនឹងប្រាក់សព្វថ្ងៃនេះជា ១១៍៧០ ។ ឯត្រកូលពីខាងដើមមិនឃើញលោកបញ្ញត្តទុកប្រហែលជាដោយឃើញថា ត្រកូលពីរនោះ ជាត្រកូលស្តុកស្តម្ភ ត្រូវកាត់យកដាច់តាមកំណត់បញ្ញត្តិដើម មិនត្រូវបន្ធូរបន្ថយកាត់គ្រប់តែការ ដូចត្រកូលពីរខាងចុង ដែលជាត្រកូលខ្សត់ខ្សោយធនធាននោះទេ ។

តែតាមបែបមួយយ៉ាងទៀត លោកចែកប្រភេទត្រកូលជា ៣ យ៉ាង គឺ ត្រកូលឧត្តមស័ក្តិ ១, ត្រកូលមធ្យមស័ក្តិ ១, ត្រកូលសាធារណស័ក្តិ ១, ។ កំណត់ត្រឹមណាជាត្រកូល

ឧត្តមស័ក្តិ ត្រឹមណាជាត្រកូលមធ្យមស័ក្តិ ត្រឹមណាជាត្រកូលសាធារណស័ក្តិ ក៏មិនដែលប្រទះឃើញបែបបទលោកចែងទុកឲ្យច្បាស់លាស់ មានត្រឹមតែឈ្មោះប៉ុណ្ណោះ តែបើធៀបនឹងត្រកូល ៤ យ៉ាងខាងដើម ក៏ល្មមនឹងអនុមានទៅបានជា ត្រកូលដែលជាប់ដោយខត្តិយត្រកូល នឹងត្រកូលដែលមានបណ្តាស័ក្តិពី ១០ ហូពាន់ចុះទៅដល់ ៦ ហូពាន់នឹងត្រកូលសេដ្ឋី គួរចាត់ជាត្រកូលឧត្តមស័ក្តិ ។ ត្រកូលដែលមានបណ្តាស័ក្តិពីត្រឹម ៥ ហូពាន់ចុះមកដល់មេស្រុក គួរចាត់ជាត្រកូលមធ្យមស័ក្តិ ។ ត្រកូលរាស្ត្រអ្នកស្រុកធម្មតា គួរចាត់ជាត្រកូលសាធារណស័ក្តិ ។

## ឋ)–·ប្រាក់ស្លាប់ទឹកដោះ :

ប្រាក់ថ្លៃទឹកដោះ ដែលមាតាបានចិញ្ចឹមមកពីតូច លុះធំឡើងមានប្តី មានទំនៀមត្រូវឲ្យកូនប្រសាប្រុស ជូនម្តាយក្មេក បើគ្មានម្តាយក្មេក ត្រូវជូនទៅឪពុកក្មេក ឬ អ្នកអាណា

ព្យាបាលប៉ុណ្ណោះ ស្រេចតែមេបាខាងស្រីនឹងកាត់ យ៉ាងតិចបំផុតពីត្រឹម ២៥០០ ឡើងទៅដល់ ១០០៥០០ មេបាត្រូវប្រមើលមើលដល់ឋានៈរបស់ត្រកូលនោះ ហើយសឹមកាត់ ឲ្យតែល្មមគួរការ ។ មានទំនៀមថា ប្រាក់ស្លាប់ទឹកដោះនោះ ម្ដាយក្មេកអ្នកទទួលទៅ មិនត្រូវយកទៅចាយវាយដោយរឿងដទៃឡើយ ត្រូវយកទៅជូនដល់មាតារបស់ខ្លួន បើគាត់ស្លាប់ទៅហើយ ត្រូវយកទៅធ្វើបុណ្យឧទ្ទិសកុសលបញ្ជូនទៅឲ្យ ។ តែបើម្ដាយក្មេកស្លាប់បាត់ទៅ ឪពុកក្មេក ឬ អ្នកអាណាព្យាបាលត្រកូលទទួលជំនួស ហើយយកទៅធ្វើបុណ្យ ឧទ្ទិសកុសលដល់អ្នកដែលស្លាប់ទៅនោះ ។

ឯគ្រឿងបណ្ដាការទាំងឡាយ ដែលរៀបរាប់មកខាងលើនេះ ជារបស់ដែលត្រូវជូនទៅខាងស្រី អ្នកសាមីដើមការ ត្រូវប្រុងប្រៀបប្រមូលមកត្រៀបត្រាទុកឲ្យបានសព្វគ្រប់ក្នុងថ្ងៃចូលពាង ។

កាលជិតនឹងដល់វេលារៀបមង្គលការ មាតាបិតាឬអ្នកអាណាព្យាបាលទាំងឡាយខាងប្រុស-ស្រី ត្រូវជំរាបញាតិសន្ដាននឹងមិត្រសម្លាញ់ទាំងឡាយ ឲ្យអញ្ជើញមកជួបជុំក្នុងថ្ងៃដែលកំណត់ទុក ។ តាមសណ្ដាប់ធ្នាប់សព្វថ្ងៃនេះ មុននឹងរៀបការ ៨ ថ្ងៃ ត្រូវប្ដឹងមន្ត្រីឃុំឲ្យចេញពតិមានបិទនៅសាលាឃុំនឹងទីដែលកូនស្រីនៅ ដើម្បីជាដំណឹងដល់អ្នកស្រុក ។

## ៧- ពិធីអាពាហ៍ពិពាហ៍មង្គល

## ថ្ងៃទី ១ ចូលរោង:

ទំនៀមការរបស់ខ្មែរនេះ តាំងពីបុរាណរៀងមក លោកកំណត់ទុកជា ៣ ថ្ងៃ ។ ថ្ងៃដំបូងហៅថាថ្ងៃចូលរោង, ថ្ងៃទី ២ ហៅថាថ្ងៃស៊ីកំណត់, ថ្ងៃទី ៣ ហៅថាថ្ងៃសំពះ ។ តែមុននឹងចូលរោង អ្នកសាមីដើមការ ត្រូវចាត់ឲ្យអ្នកជំនូវស្រី នៅជំរាបជូនផ្ទះ នឹងសុំអនុញ្ញាតកិច្ចការផ្សេង ១ ដល់មេបាខាងស្រី គឺ:

ការៈដំបូង : ត្រូវដំការបជូនផ្ទះដែលសង់ថ្មីនោះទៅមេបា (តែស្រុកខ្លះ គេឲ្យជូនក្នុងថ្ងៃទី ២) ។

ការៈទី ២ : ត្រូវសូមទីដី ជើងទឹក ជើងគោក សម្រាប់ធ្វើការ គឺសុំព្រៃកខុស សុំកំពង់ដងទឹក សុំដីជីកគុក សុំដីជីកដើក្រាន និងសុំសង់រោងផ្កាស្លា និងសង់រានទេវតា ។

ការៈទី ៣ : សុំស្បូវខ្សែក្រទ ខ្សែចាប៉ី គោះគងខ្ចង់ភេរី នាំអ្នកសាមីខ្លួន និងកស្តុការបណ្តាការ ចូលរោងមង្គលការ គឺរោងផ្កាស្លា ។

ការៈទី ៤ : ត្រូវសុំផ្ទះលោកមេបានឹងរៀបចំធ្វើមង្គលការ ។

ការៈទី ៥ : ត្រូវសុំឲ្យលោកមេបាប្រមូលញាតិសន្តានឲ្យអញ្ជើញមកជួបជុំ ក្នុងថ្ងៃព្រឹកស្អែកឯណោះ និងបានសែនព្រេនជូនតានៅលើស្លាដក់ ស្លាកន្សែង ស្លាជង់រង ជូនពិសាតាមទំនៀម ។ ក្នុង១ចាំងប៉ុន្មានដែលអ្នកផ្លូវសុំនោះ បើជាការមិនខុសទាស់និងច្បាប់ប្តូរទំនៀមទម្លាប់ មេបាត្រូវអនុញ្ញាត

ឲ្យដាច់ពាក្យ ។

## ១)- ថ្ងៃទី ២ ស៊ីកំណត់

ថ្ងៃទី២ វេលាព្រឹកក្នុងកាលម៉ោង៧ ទៅម៉ោង៨ ជាវេលាដែលត្រូវសែនព្រេនជូនតានិងស៊ីស្លាដក់ ស្លាកន្ទ្រង ស្លាបន់ ផងកំណត់ គេហៅថា «ស៊ីស្លាកំណត់» ឲ្យខ្ញី ។ ត្រូវឲ្យអ្នកសាមីដើមការនាំភស្តុការទៅផងនោះ ព្រមដោយខន្ធភោជនីយាហារ គឺចំណាប ២ ជាល ឬ២ត្រា, បង្អែម ២ ជាល ឬ ២ ត្រា, មាន់ស្ងោរ ១ ក្បាល, ទាស្ងោរ ១ ក្បាល, សាច់ជ្រូក ១ ភ្លៅ ទៅរៀបនៅស្នួនផ្ទះការនោះ ស្រេចហើយឲ្យអ្នកស្លូទៅនិយាយការនឹងមេបា តាមទំនៀមដូច្នេះ :

ការៈដំបូង : អ្នកស្លូត្រូវនិយាយថា : ពីថ្ងៃម្សិលមិញ សាមីដើមការ បានពឹងពរកខ្ញុំទាំង ៣ នាក់ ឲ្យជាអ្នកផ្លូវមកសុំដី ជើងទឹក ជើងគោក រហូតដល់ទៅ

សុំប្រមូលញាតិសន្ដាន ដូចមានកំណត់ជូនពីថ្ងៃមុន ស្រាប់ ។

ការៈទី ២ : ត្រូវបន្តួយសណ្ដើរចាស់ ផ្លាស់ដាក់សណ្ដើរថ្មី សុំបន្តួយទញ្ញាំងស្រូវ សុំចងភ្ជាប់ដៃ សុំក្រាលកន្ទេលជូន លោកមេបា នឹងបាននិយាយបន្តលការតទៅ (តែទំនៀមខ្លះ ម្អុកខ្លះ ក្នុងការៈទី ២ នេះ គេជូនផ្ទះការទៅមេបា ការៈទី ៣ ទើបសុំបន្តួយទញ្ញាំង ។ ល ។

ការៈទី ៣ : ត្រូវសុំឲ្យលោកមេបាប្រមូលញាតិសន្ដាន ។

ការៈទី ៤ : ថាវេលានេះល្មមនឹងសែនព្រេនចាស់ទុំហើយ សូមអញ្ជើញអស់លោកមេបាសែនព្រេន ។

ក្នុងខណៈនោះ ពួកមេបាត្រូវប្រមូលភ្ជាប់សែនព្រេនដោយ ខ្ជួរភោជនីយាហារនិងលតោលហើយ គឺសែនដំណាប់លើកជល់ ជីដូននិងជីតាជាដើម ដែលធ្វើកាលកិរិយាទៅហើយ ឲ្យបាន

ប្រាប់ទូទៅ ឱ្យគេបានដឹងរៀបមង្គលការកូនចៅ កុំឲ្យប្រកាន់ថាជាការអ្វីឡើយ ។

ការៈទី ៥ : កាលបើសែនព្រេនរួចហើយ ត្រូវជំរាបតទៅទៀតថា វេលាល្មមនឹងលើកស្លាដក់ ស្លាកន្សែង បង់រងកំណត់ជូនពិសាហើយ តើទំនៀមលោកមេបានឹងពិសានៅល្វែងណា? សូមមានប្រសាសន៍ ។

ត្រង់នេះមានទំនៀមថា : ស្លាដក់ ស្លាកន្សែង ត្រូវស៊ីនៅល្វែងខ្លៀង, ស្លាជន់ទេ កំណត់ត្រូវស៊ីនៅល្វែងចិន គឺល្វែងកណ្តាល ។ ១ នេះស្រេចនៅលើមេបា នឹងស៊ីបែកផ្ទះក៏បាន នឹងស៊ីរួមក៏បាន បើស៊ីរួមត្រូវរួមទៅស៊ីនៅល្វែងចិនតែមួយ ត្រូវប្រាប់ទៅអ្នកផ្ទះវិញតាមការ ។

ន័យមួយទៀតមានទំនៀមថា កាលភ្ញៀវការមកដល់ត្រង់នេះហើយ ត្រូវផ្លាស់អ្នកផ្ទះស្រីចេញ បញ្ចូលអ្នកមហាប្រុស

៣ នាក់ចូលជំនួស ព្រោះលោកថា អ្នកផ្លូវស្រីនោះមាន
អំណាចនិយាយការបានតែត្រឹមល្បែងធ្មៀន តែសព្វថ្ងៃនេះ គេ
ច្រើនប្រើអ្នកផ្លូវប្រុសតែម្ដង តាំងពីដំបូងមក ដោយហេតុនឹងរក
ស្រីដែលចេះនិយាយការក្នុងរឿងនោះបានដោយក្រ ចំណែក
ឯប្រុសដែលធ្វើការជំនួសអ្នកផ្លូវស្រីនោះ ត្រូវប្ដីមេបាតាំងពី
ដំបូងថា នឹងរកស្រីព្រហ្មចារី ដែលចេះស្រដីការគ្រប់
ជំពូកមកធ្វើជាអ្នកផ្លូវជូនលោកមេបាពុំបាន នឹងរក
ស្រីចាស់ក៏រវល់ណាស់តែកូនយំ ហេតុនេះខ្ញុំប្របាទ
សូមនិយាយការទាំងពួងជំនួសអ្នកផ្លូវស្រី ។

មេបាត្រូវអនុញ្ញាតឲ្យ តែអ្នកផ្លូវប្រុសនោះត្រូវនិយាយ
ការជាភាពស្រីរហូតមក ។ កាលមកដល់ត្រង់ស៊ីកំណត់នេះ
ត្រូវផ្លាស់ភាពជាមេបាប្រុសវិញ ត្រង់នេះមានទំនៀមថាមេបា
ត្រូវបង្គាប់ឲ្យអ្នកមេបានេះ រកតាំងយូ ស្បែកជើង សំពត់

ហូលដរ ៣ ជាន់ សារ៉ាយ ចង់រង ដ៏ជាគ្រឿងប្រដាប់សម្រាប់អ្នកមហាឲ្យបានមកសព្វគ្រប់ មេបាន៍ងបានតាំងជាមហាពេញយស កាលរកបានហើយ មេបាត្រូវតាំងអ្នកទី ១ ជាមហាទេព,(១) អ្នកទី២ ជាមហាមន្ត្រី, អ្នកទី ៣ ជាមហាប្រះពាន បើរកគ្រឿងប្រដាប់ទាំងអំបាលនោះមិនបាន ឬបានខ្លះខ្វះខ្លះ ត្រូវប្តឹងទៅមេបាតាមការ មេបាត្រូវអនុញ្ញាតឲ្យតាមមានតាមបាន ។ គ្រឿងសំលៀកបំពាក់អ្នកមហានោះដូចម្តេចខ្លះ ដូចមានពោលហើយខាងដើម ។

១– ទំនៀមរាជការក្នុងព្រះបរមរាជវាំងសព្វថ្ងៃនេះ ឃើញតាំងងារមហាមន្ត្រីជាចាងហ្វាងស្តាំ ងារមហាទេពជាចាងហ្វាងឆ្វេងជួយគ្នានឹងងារអ្នកមហាក្នុងទម្រង់ការនេះ កំរំណាងងារមហារមន្ត្រី មហាទេព ក៏មានមុខក្រសួងក្នុងរឿងនេះដែរ ហេតុម្តេចក៏ត្រឡប់ជួយគ្នាទៅវិញ តែបើគិតមើលតាមទម្លាប់ដែលអ្នកស្រុកហៅសព្វថ្ងៃនេះ ឃើញហៅងារមហាទេពមុនដូចគ្នានឹងទម្រង់ការ ឬបើនឹងគិតមើលតាមរូបឈ្មោះទាំងពីរនោះក៏ឃើញគួរឲ្យងារមហាទេពជាស្តាំ ។ ងារនេះក្នុងជំនាន់ដើមប្រហែលជាមហាទេពនៅមុខ ទើបត្រឡប់មកផ្លាស់គ្នាក្នុងរជ្ជកាល ៦ណា និមួយទេដឹង ។

ការៈទី ៦ៈ ត្រូវថ្លែងថា តើទ្រព្យនេះភស្តុភារបណ្ណាការ ស្លាដក់ ស្លាកន្សែង ស្លាបិដរងកំណាត់ គ្រប់គ្រឿង ដ៏ប្រពៃមូលមកសព្វគ្រប់ហើយ សូមលោកមេបាពិត ពិលរមិលមើល បើឃើញខ្វះខាតនឹងបំពេញជូន តាមការ ។

ខណៈនោះមេបាស្រី ត្រួតត្រាមើលគ្រឿងស្លាម្លូ មេបាប្រុស ត្រួតមើលគ្រឿងបណ្ណាការឯទៀត រួចហើយអ្នកមហាត្រូវលើកគ្រឿងស្លាជូនទៅមេបាពិសាតាមទំនៀម មេបាត្រូវចៀកម្លូពិសានូវទៅគ្រប់គ្នា ។

តាមរបៀបទម្រង់ការច្បាប់ជ័យសួស្ដី មានបន្ទាប់ទុកឲ្យលេងភ្លេងផ្សេងៗ ក្នុងពេលនោះៗ ដូចនឹងមានពោលដោយលំដាប់ទៅ ក៏ក្នុងឱកាសស៊ីកំណាត់នេះ លោកថាត្រូវលេងភ្លេងជ្រើសដើមបទ ជ្រុងគរម្ងាត់ ។

ភារៈទី៧ : ត្រូវដឹកនាំមេបាឲ្យរៀបអង្គុយ នឹងបានរៀបស្លក ក្រយាជូនពិសា ។ ពួកមេបាត្រូវរៀបគ្នាពិសាបាយ ។ ក្នុងឱកាសនេះ អ្នកភ្លេងត្រូវលេងភ្លេងជ្រងដើមបទមួយបទ, ជ្រងសម្ពាត់ ៣ បទ, ដោះក្រាល ៣ បទ ។

ប៉ុណ្ណោះឈ្មោះ ថា បានពាក់កណ្ដាលការហើយ ប្រសិនជាមានហេតុចលាចលក្នុងពិធីពាក់កណ្ដាល ដោយប្រការឯណាក្តី មកបណ្ដាលឲ្យអាក់ខានរៀបការទៅ លោកអនុញ្ញាតទុកឲ្យថា មេបាអាចនឹងចាប់ក្បាលអ្នកសាមីខ្លួនទន្ទិចគ្នា ឲ្យយកគ្នាជាប្តីប្រពន្ធបាន ។

ក្នុងវេលារសៀល ក្នុងថ្ងៃដដែលនេះ អ្នកដើមការត្រូវចាត់ចែងគ្រឿងបណ្ដាការការធំ នឹងគ្រឿងស្លាព្រះពរស្លាដីយ ព្រមទាំងខ្លាផ្កាស្លាម្លូយផង ឲ្យមនុស្សយកទៅរៀបលើផ្ទះការ ហើយឲ្យអ្នកមហាទៅដឹកប្អូនមេបា ។

ភារៈដំបូង អ្នកមហាត្រូវដឹកនាំមេបា ឲ្យត្រួតត្រាមើល

បណ្ដាការ បើខ្វះភាគនឹងថែមឡើង ៗ មេបាត្រូវត្រួតត្រា មើល កាលណាបើឃើញត្រឹមត្រូវសព្វគ្រប់ដូច ១ បន្ទាប់ដើម ហើយ ត្រូវទទួលយកអំពីអ្នកមហា ហើយចាត់ការទៅតាម រឿន គឺគ្រឿងបណ្ដាការការធំ ត្រូវប្រគល់ឲ្យមាតាបិតា ឬអ្នកអាណាព្យាបាលកូនស្រី យកទៅសម្រាប់ទទួលភ្ញៀវ ស្លាព្រះពរត្រូវទុកយកទៅថ្វាយព្រះរតនត្រ័យ ក្នុងវេលា ដែលព្រះសង្ឃមកចំរើនព្រះបរិត្តក្នុងវេលាតទៅ ៗ ឯគ្រឿង ស្លាជ័យលោកថា ត្រូវបានមេបាធំដែលនិយាយការគ្រប់ជំពូក រីតលោកខ្ញុំទុកថា មេបាដែលត្រូវបានស្លាជ័យនោះ ត្រូវឲ្យ មានប្រាក់ដួង ១ ទុកដើម្បីនឹងបញ្ជាប់ព្រលឹងអ្នកសាមីខ្លួន វិញកុំខាន សម័យនេះគ្មានប្រាក់ដួង នឹងប្រើប្រាក់រៀល ប្រាក់កាក់ជំនួសក៏បាន ។ ខ្ពុំក្ដោស្លាឲ្យរៀបក្នុងពិធីសូត្រមន្ត ក្នុងវេលានេះ ត្រូវលេងភ្លេងនគររាជ, ភ្លេងស្ដេចផ្ទុំ, ភ្លេងកង-សោយ ។

ការៈទី ២ ត្រូវសូមអនុញ្ញាតកាត់សក់កូនប្រុស-ស្រី ។ តែបើកូនស្រីនោះទុកសក់ខ្លួន ត្រូវសូមអនុញ្ញាតតែកាត់កូនប្រុស ។ របៀបកាត់សក់នោះ ខណៈនឹងផ្តើមកាត់ ជាងអ្នកកាត់ត្រូវកាន់កន្ត្រៃ កាន់ក្រាស់ច្រៀងកន្លងកិរិយាបាក់ដូចជានឹងកាត់បានពាបទ ហើយទើបកាត់ទៅទាល់តែហើយ បើជាងកាត់មិនចេះច្រៀង មិនចេះរាំ ត្រូវរកអ្នកឯណាច្រៀងរាំជំនួស ធ្វើកិរិយាដូចពោលមកហើយ កាលគ្រប់ការៈហើយ ជាងត្រូវទទួលកាត់តទៅ ។ ក្នុងខណៈកាត់សក់នោះ អ្នកលេងភ្លេងត្រូវលេងភ្លេងស្រីស្មើរ ភ្លេងសារិកាកែវ ភ្លេងកាត់សក់ ។

ការៈទី៣ ត្រូវសូមអនុញ្ញាតពលិការដល់អ្នកតាចាស់ស្រុកទឹងក្រុងពាលី ។ របៀបពលិកាអ្នកតាចាស់ស្រុកនោះ ត្រូវវិហាកូនប្រុសទៅកាន់ខ្ទមអ្នកតា បើគ្មានអ្នកតានៅជិត គប្បីទៅកាន់ទីដើមឈើធំ ឬទីដីទួលណាមួយដ៏សមគួរ ដែលនៅជិតផ្ទះនោះ ព្រមដោយគ្រឿងដង្វាយ គឺ ក្បាលជ្រូក១, មាន់

ស្លា ១, ចង្អាប ១ ចាស, បង្អែម ១ ចាស, ទឹក ១ ផ្តិលនឹង ប្រអប់ស្លា ១ កាលទៅដល់ហើយ អ្នកមហាត្រូវថ្លែងសំពះថា ដ្បិតវេលានេះយើងខ្ញុំនឹងរៀបមង្គលការ កូនប្រុស-ស្រី សូមសំ-ពះអ្នកតាចាស់ស្រុកកុំឲ្យប្រកាន់ថាឆាវខ្វី សូមឲ្យសុខសប្បាយ ទាំងអស់គ្នារៀងទៅ កុំឲ្យមានមោះខ្លួសការអ្វីឡើយ ។ ហេតុដែលមានរបៀបពិលិការដល់ក្រុងពាលីនោះ ត្រូវមាន តែពែមួយដាក់គ្រឿងសំណែន គឺបាយសម្ល ហើយត្រូវរៀប សែននៅទីដីក្បែរផ្ទះការ ក្រង់ល្វែងជ័ន ទាំងខាងប្រុស-ស្រី ត្រូវប្រួមគ្នាសែន ឬតែខាងឯណានីមួយសែនជំនួសក៏បាន វេលាសែនហើយ ត្រូវឲ្យជីកដីកប់ពែនោះនៅក្រោមប្រមាណជា មួយចំអាម តែអ្នកខ្លះគេមិនកប់ គេគ្រាន់តែយកអាចម៍ដីមក គ្របពីលើក៏មាន ។ ក្នុងវេលាសែននោះ អ្នកភ្លេងត្រូវលេង ភ្លេងឆ្លង ភ្លេងនារី ភ្លេងស្ដេចដើរ ។

រឿងសែនក្រុងពាលីនេះ មានពោលពិស្ដារក្នុងក្រប្រា

ដោយឡែកផ្សេង ៗ

ការៈទី៤ ត្រូវសូមអនុញ្ញាតសូត្រមន្ត ៗ ទំនៀមដើម ខាងប្រុសគេសូត្រឯកោទត្ថាគ្លា ខាងស្រីគេសូត្រនៅផ្ទះការ តែសព្វថ្ងៃនេះ គេច្រើនតែរួមគ្នាសូត្រនៅផ្ទះតែម្តង ដើម្បីកាត់បន្ថយឲ្យតិចចុះ សូត្រញែក ឬសូត្ររួមគ្នា អ្នកមហាត្រូវសូមអនុញ្ញាតតាមនោះ ៗ ក្នុងវេលាសូត្រមន្តអ្នកសាមីខ្លួនទាំងពីរនាក់ត្រូវចេញមកស្តាប់ ព្រះសង្ឃដែលសូត្រមន្តកំណត់យកប៉ុន្មានរូប សព្វថ្ងៃនេះឃើញគេច្រើនយក ៥ រូប ដូចកិច្ចសូត្រមន្តក្នុងរឿងដទៃ តែបើកំណត់ឲ្យគួរតាមរឿងការនេះ ត្រូវយកឲ្យគត់គូគឺ ៤ រូប, ៦ រូប, ៨ រូប, ១០ រូប ទើបត្រូវតាមរឿងផ្សំគូ ៗ គ្រឿងស្លាព្រះពរត្រូវយកមកប្រគេនព្រះសង្ឃដែលសូត្រមន្តនេះ ៗ

ដល់ពេលព្រលប់ក្នុងកាលម៉ោង ៦ អ្នកមហាត្រូវឡើងពោលនិយាយការនឹងមេបាទៀត ៗ

ភារៈដំបូង ត្រូវសុំអនុញ្ញាតធ្វើពិធីចងដៃកូនប្រុស-ស្រី គឺកូនប្រុស ត្រូវចងដៃនៅខាងស្តាំ, កូនស្រីត្រូវចងដៃឆ្វេង ផ្ទះការ ៗ ក្នុងវេលាចងដៃនេះក្តី វេលាចេញផ្ទឹមនេះក្តី ក្នុងថ្ងៃស្អែកឯណាក្តី សាមីខ្លួនកូនប្រុស-ស្រីត្រូវស្អាងកាយ យ៉ាងពេញទីតាមទំនៀម គឺ ទាំងកូនប្រុស-ស្រី ត្រូវស្លៀកសំពត់ពាក់អាវពណ៌ក្រហមសុទ្ធ ឬពណ៌ណាយដោយពណ៌ក្រហម សំពត់ដែលធ្លាប់ប្រើមកហើយ គឺសំពត់ល្បើក សំពត់ផាមួង សំពត់ហូល សំពត់សារបាប់ជាដើម ហើយត្រូវស្លៀកសំឡុយទាំងពីរនាក់ ហាមមិនឲ្យស្លៀកចងក្បិន ដូចការប្រក្រតី ៗ ចំណែកឯអាវ កូនប្រុសត្រូវពាក់អាវប្រែ អាវល្បើក អាវផ្កាមាស ផ្កាប្រាក់ អាវសារបាប់ជាដើម ឯណានិមួយ ហើយពាក់អាវផាយក្រហម ១ ជាន់ទៀត កូនស្រីត្រូវពាក់អាវប្រែ, ស្បៃ ឯណានិមួយក៏បាន តែអ្នកមានគេច្រើនប្រើស្បៃ តែងភាពជាកូនឈ្នួន ក្បាលប្រដាប់ដោយរបៃ

ស្លាបក្រអោមក៏មាន រំបែអង្គាំក៏មាន រំបែខ្ចិនក៏មាន ក្បាំងណាក៏មាន តែអ្នកស្រុកក្រុងសម័យឥឡូវនេះគេមិនយកប្រដាប់ប្រដារមកតាក់តែងក្បាល ឲ្យរយោងយោងច្រើនដូចសម័យបុរាណទេ ក្រៅពីនេះ កូនប្រុសត្រូវយកប្រដាប់មានចិញ្ចៀនដ៏មានដម្លៃផ្សេងៗជាច្រើនវង់ នឹងក្រវាត់ខ្សែក្រវាត់មាសប្រាក់ជាដើម កូនស្រី ត្រូវតែងខ្លួនប្រដាប់ដោយខ្សែក ខ្សែដៃ ទំហូ ចិញ្ចៀន នឹងក្រវាត់ខ្សែក្រវាត់មាសប្រាក់ជាដើម យ៉ាងច្រាលរន្ទាល ។

ឯរបៀបចងដៃ ដែលអ្នកមហាសុំអនុញ្ញាតអម្បាញមិញនោះ ត្រូវមានរបៀបដូច្នេះគឺ ចំអាប២ហិស ឬ ២តុ, បង្អែម ២ហិស ឬ ២តុ, អ្នកសាមីខ្លួនត្រូវចេញមកក្រាបនៅកណ្ដាលទីប្រជុំអស់លោកមេបា ពួកមេបានាំគ្នាសែនព្រេន ជីដូនជីតារួចហើយ ត្រូវយកអំបោះសចងដៃអ្នកសាមីខ្លួន ក្នុងៈផណាដែលពួកមេបាកំពុងចងដៃនោះ អ្នកភ្លេងត្រូវលេងភ្លេង

បទផាត់ជាយ, ភ្លេងបាយខុន ។

ក្នុងវេលាម៉ោង៧ ទៅម៉ោង៨យប់ គ្រូសៀងក្មៀវដែលអញ្ជើញមកជាកិត្តិយសក្នុងពិធីមង្គលការនោះ ពួកក្មៀវទាំងប៉ុន្មានកាលបើទទួលគ្រួសារស្រូបនិងស្លៀងរួចហើយ គ្រូចងដៃបញ្ចប់ព្រលឹងដល់កូនប្រុស.ស្រី ដោយប្រាក់កាសម្ពរបស់ទ្រព្យផ្សេងៗ ។ រឿងចងដៃបញ្ចប់ព្រលឹងក្នុងពិធីរៀបមង្គលការនេះ ជាការគួរសមណាស់ ឈ្មោះថាការសង្គ្រោះដល់ប្ដីប្រពន្ធជាគូថ្មីនេះ ព្រោះអ្នកដែលមានគ្រួសារហើយ គ្រូរ៉ែមកបញ្ញើជាតាមិតាម្ដាយគាកណាញាតិទាល់ទៅនៅរកស៊ីជាឥស្សរភាពចំពោះខ្លួនឯង កាលពួកញាតិមិត្តនាំយកប្រាក់កាសនឹងទ្រព្យរបស់ផ្សេងៗមកឲ្យ ក៏នឹងបានជាដើមទុន រកស៊ីតាំងខ្លួនឯងតទៅ ទំនៀមនេះ គួរនាំគ្នាធ្វើតទៅ កុំបីបោះបង់ចោល ។

ប៉ុន្តែ.......

ក្នុងកាលម៉ោង១២យប់ បើតាមខ្លួនកូនស្រីនោះ មិន

ដែលធ្វើឆ្អេញទេតាំងពីក្មេងមក កោចាប្រត្រូវរៀបធ្វើឆ្អេញឲ្យ ក្នុងឱកាសនោះ របៀបធ្វើឆ្អេញនោះដូចម្តេច មានពណ៌នា ក្នុងរឿងកូនស្រីចូលម្លប់រលោះ តែទំនៀមនេះគេបានបោះ បង់ចោលជាច្រើន មិនសូវធ្វើទេ ។

ការៈទី ២ ក្នុងកាត់ម៉ោង១០យប់ អ្នកមហាគ្រូសុំអនុ-ញ្ញាតរៀបរៀងខ្លែងឈើ ក្នុងទីនេះសំដៅយក នំផ្សេងៗដែល គេធ្វើជាកញ្ចប់ៗ តាមទំនៀមបុរាណ លោកជ្រើសរើស យកស្រី ជំទង់ ក្រមុំ ប្រុសជំទង់ កំលោះ ដែលមាំសុទ្ធបីដូច ជាព្រហ្មនៅព្រហ្មលោក គឺស្រីមិនធ្លាប់មានប្រុស ប្រុសដែល មិនធ្លាប់មានស្រី ដែលហៅតាមភាសាបាលីថា ព្រហ្មចារី អ្នកប្រព្រឹត្តដូចព្រហ្ម ស្រីយក៤នាក់ មកសន្មតឈ្មោះជា នាងកែវ នាងកង នាងមាស នាងប្រាក់ ប្រុសយក ៤ នាក់ សន្មតឈ្មោះជា ចៅមាន ចៅបាន ចៅសុខ ចៅជ័យ និង ត្រូវយកអ្នកមហាធំទាំងពីរនាក់ ឲ្យធ្វើជាចៅមឿង គឺជាការឯបក៏

ឲ្យជាអ្នករៀបរៀងថ្លៃឈើ ។ ការរើសយកស្រី-ប្រុស មក
សន្មតឈ្មោះទៅផ្សេងៗ ឲ្យជាអ្នករៀបរៀងថ្លៃឈើនោះដើម្បី
ជាប្រផ្នូល ឲ្យភរិយា ស្វាមី គូថ្មីនោះ បាននូវសេចក្ដីត្រជាក់
ត្រជុំ សេចក្ដីមានបាន សេចក្ដីសុខសួស្ដី ជ័យមង្គលប៉ុណ្ណោះ
ឯង ។ ក្នុងវេលារៀបរៀងថ្លៃឈើ អ្នកភ្លេងត្រូវលេងភ្លេង
ប៉ុកពើក ភ្លេងមួយម៉ឺង ភ្លេងស្វាយកន្ទុំរត្ត តែគប្រមាខ្លះគ្មាន
ភ្លេងប៉ុកពើត ដាក់ភ្លេងសារិកាកែវជំនួស ។

ការៈទី៣ ត្រូវសុំអនុញ្ញាតជាវខាន់ស្លា ឬ ហៅថាកាត់
ខាន់ស្លា គឺសុំឲ្យមេបាកាត់ចំនួនប្រាក់ ដែលត្រូវឲ្យសាមីខ្លួន
ដើមការយកមកដាក់ខាន់-ស្លា គឺ ថ្លឹលស្លា ជូនមេបា ។
តាមទំនៀមបុរាណគេកាត់ជាប្រាក់ ១២ ដំឡឹង សម័យនេះគេ
ច្រើនកាត់ ១ ណែន គិតប្រាក់ពយ ១៥០០ ឬ ១៦០០ តែ
គេអាចនឹងបន្ថយឲ្យដាក់ច្រើនទៅទៀតក៏បាន ទៅតាមធនធាន
សាមីដើមការ ប្រាក់នេះត្រូវយកមកជូនលោកមេបាក្នុងពេល

ព្រឹកឯណោះ ហើយគ្រូបានទៅហៅតាបិតា ឬអាណាព្យាបាល ។ ក្នុងវេលាកាត់ខាន់ស្លា លោកឲ្យលេងភ្លេងបទនគររាជ ភ្លេងខ្លងបរិណ្ណត ភ្លេងកងសោយ ។

ការៈទី ៤ គ្រូសុំឲ្យមេបាជំនុំពេលា ពីកំណត់ពេលវេលា ឲ្យមេបាស្រាបខ្ញូទៅ ដើម្បីនឹងបានរៀបកូនស្រី ឲ្យទាំទទួលពេលា តាមដែលកំណត់ទុកដោយព្រមព្រៀង តាមទំនៀមគេកំណត់យកក្នុងវេលាអរុណរះថ្ងៃព្រឹកឡើងឯណោះ ។

លំដាប់ពីនោះ វេលាទៀបភ្លឺអ្នកសាមីជើបការគ្រួកូនស្រី អ្នកដែលបានរៀបការដោយមានខាន់ស្លា ហើយមានជីវិតរស់នៅទាំងពីរនាក់នោះផង យកដោតផ្កាស្លានៅរោងផ្កាស្លា នៅព្រានល្វែងដើម ពីល្វែងកណ្តាល អ្នកដោតត្រូវចាក់ដោតជា ៣ សំណុំ គឺ យកខ្លួនផ្កាស្លា ដែលដាក់សូត្រមន្តពីពេលល្ងាចនោះ មកកាត់ចេញហើយយកអម្បោះសចង បង្ហាជុំ

ហើយដាក់ចុះក្នុងកែវមួយៗ ហើយត្រូវដោតផ្លែស្លាខ្ចី ឬស្លាស្ងួត នឹងស្លឹកម្លូជុំវិញផ្កានោះ ។ តាមក្បួនបុរាណ១ទៀត ផ្កាទី១ ត្រូវដោតផ្លែស្លា២១ផ្លែ ម្លូ២១សន្លឹក ។ ផ្កាទី២ ត្រូវដោតផ្លែស្លា១២ផ្លែ ម្លូ១២សន្លឹក ។ ផ្កាទី៣ ត្រូវដោតផ្លែស្លា ៦ ម្លូ ៦ សន្លឹក ។

តាមសេចក្តីអធិប្បាយរបស់លោក-អ្នកតែងក្បួននោះថា ដែលឲ្យដោតផ្លែស្លា ២១ តាមចំនួនគុណរបស់បិតា ព្រោះផ្កានេះធ្វើឡើងតម្រូវនឹងបូជាគុណបិតា ឲ្យដោតផ្លែ ១២ តាមចំនួនគុណមាតា ព្រោះផ្កានេះតម្រូវនឹងបូជាគុណមាតាឲ្យដោត

ថ្លែងតាមចំនួនគុណបង ព្រោះផ្កានេះតម្រូវនឹងធាតុគុណបង(១), តែតាមក្បួនខ្លះ ឬតាមគតិអាចារ្យខ្លះថា ផ្កាស្លាទី១ ត្រូវដោតថ្លៃស្លា ៩, ទី ២ ត្រូវដោតថ្លៃស្លា ៧, ទី ៣ ត្រូវដោតថ្លៃស្លា ៥ ។ ផ្កាស្លាទាំង ៣ នេះមានឈ្មោះ ថិថលក

---

១– គេសន្មតយកធាតុដី ២១ ក្នុងខ្លួនមនុស្ស គឺ ១ សក់, ២ រោម, ៣ ក្រចក, ៤ ធ្មេញ, ៥ ស្បែក, ៦ សាច់, ៧ សរសៃ, ៨ ឆ្អឹង, ៩ ខួរក្នុងឆ្អឹង, ១០ ទាច, ១១ បេះដូង, ១២ ថ្លើម, ១៣ វាវ, ១៤ ក្រពះ, ១៥ សួត, ១៦ ពោះវៀនធំ, ១៧ សរសៃវិតពោះវៀន, ១៨ អាហារថ្មី, ១៩ អាហារចាស់, ថែមឆ្អឹងលលាដ៍ក្បាលនឹងខួរក្នុងលលាដ៍ក្បាល ជា ២១ ជាគុណបិតា ។

គេសន្មតយកធាតុទឹក១២ក្នុងខ្លួនមនុស្ស គឺ ១ ទឹកប្រមាត់, ២ស្លេស, ៣ ខ្ទុះ, ៤ ឈាម, ៥ ញើស, ៦ ខ្លាញ់ខាប់, ៧ ទឹកភ្នែក, ៨ ខ្លាញ់រាវ, ៩ ទឹកមាត់, ១០ ទឹកសំបោ, ១១ ទឹករំអិល, ១២ ទឹកមូត្រ ។

គេសន្មតយកធាតុខ្យល់ ៦ ក្នុងខ្លួនមនុស្ស គឺ ១ ខ្យល់បក់ឡើងលើ, ២ ខ្យល់បក់ចុះក្រោម, ៣ ខ្យល់បក់ក្នុងពោះ, ៤ ខ្យល់បក់ក្នុងសរសៃ, ៥ ខ្យល់បក់ទូទៅ ក្នុងអវយវៈធំតូច, ៦ ខ្យល់ដង្ហើមចេញចូល ។ កាលដែលបញ្ញត្តយកធាតុអម្បាលនេះមកជាគុណមាតា-បិតា – បង ដូចនេះ មិនមែនជាពុទ្ធដីកាព្រះទេ ជាគតិរបស់អាចារ្យខ្លះបញ្ញត្តឡើង ។

ហៅតាមលំដាប់ធំតូចជាន់គ្នា ផ្កាស្លាច្បង ផ្កាស្លាកណ្តាល ផ្កាស្លាពៅដូច្នេះក៏មាន ។ ទំហំដោតផ្កាស្លាមានទំហំផ្សេងគ្នា តាមស័ក្តិអ្នកសោយខ្លួន គឺអ្នកដែលជាអំបូរឧត្តមសក្តិ ត្រូវដោតសំយាកចុងផ្កា ដែលជាអំបូរមធ្យមសក្តិ និងសា-ធារណសក្តិ ត្រូវដោតត្រួយចុងផ្កាស្លាដូចគ្នា ។ ក្នុងវេលាដោតផ្កាស្លា អ្នកភ្លេងត្រូវលេងភ្លេងនាងនក់, ភ្លេងសំពោង, ភ្លេងដំរីយោលដៃ ។

កាលរៀបដោតផ្កាស្លារួចហើយ ត្រូវរៀបរណ្តាប់ផ្សេងៗ ដែលត្រូវស្លូននឹងត្រូវប្រើ ក្នុងវេលាព្រឹកនោះ គឺទ្រាក់ទាន់ស្លា, ទ្រាក់ស្លាប់ទឹកដោះ និងរៀបគ្រឿងបាយព្រលឹង ១ សម្រាប់ មានកន្ទោងដាក់បាយ ១៩ ពំនូត និងផ្លែឈើទំ ផ្សេងៗគ្រប់មុខ, ស្លា ៩ ផ្លែ, ម្លូ ៨ សន្លឹក, ទៀន ១ គូ, និងរៀបព្រះពិស្ណុការ មួយទៀតដាក់គ្រឿងចំអាប គឺមាន់ស្ងោរ ១ និងស្រាមួយកំប៉ុក ។ ចំណែកឯខាងស្រី

ក្នុងពេលជាមួយគ្នានេះ ក៏ត្រូវរៀបគស្ការសម្រាប់ខ្លួនដែរ គឺត្រូវរៀបបាយសី (បាយស្រី) មានរណ្ដាប់គឺបាយ១៩ពំនូក យកល្ង សណ្ដែក ដូង ដែលលីងបុកល្អិតហើយមករោយ លើពំនូកបាយនោះ និងស្លា ១៩ ផ្លែ ម្លូ ១៩ សន្លឹក ទំពៅ ១៩ កង់ ផ្លែចេកក្រអូប ៩ ផ្កា ៥ ទៀន ១ គូ ។ របស់សំម្យាលនេះត្រូវរៀបទុកនៅកន្លែងកូនស្រី (ជារណ្ដាប់សម្រាប់ផ្សំដំណេកក្នុងវេលាយប់នោះឯង) ។

## គ)- ពិធី ៣ សំពះ

ដល់វេលាភ្លឺស្រាង ដែលហៅថាអរុណរះ អាចារ្យអ្នកកាន់ពេលា ត្រូវនាំកូនប្រុសទៅថ្វាយបង្គំកនទេវតាដែលធ្វើទុកពីថ្ងៃមុន នៅទីរៀបផ្ទះការនោះ ដែលមានគ្រឿងតង្វាយ គឺបាយសី ៥ ថ្នាក់១គូ, ស្លាធម៌ ១ គូ, ទឹកអប់១គូ ទៀន ៥, ធូប ៥, លាជ ៥, ផ្កា ៥, ស្លាធីប ១ ជើងពាន ដាក់ថ្វាយនៅលើពាននោះ និងត្រូវអង្គុយចាំយកពេលានៅទីនោះផង

របៀបអង្គុយរង់ចាំពេលា តាមទំនៀមបុរាណ គេឲ្យអង្គុយលើត្បាល់ ពីយកត្បាល់មកផ្កាប់ ហើយក្រាលសំពត់ពីលើ ឲ្យអ្នកគាប់ខ្លួនអង្គុយសំយុងជើង បែរមុខទៅទិសបូព៌ តែមកក្នុងសម័យនេះគេឲ្យឈរក៏មាន ចាំមើលសុរិយកាល គឺវេលាដែលព្រះអាទិត្យរះ ដោយបុរាណាចារ្យលោកកំណត់ទុកថាត្រូវយកពេលានោះ ព្រោះជាពេលដ៏បរិសុទ្ធ ជាពេលមង្គល ដើម្បីជាប្រផ្នូលឲ្យកូនប្រុសស្រី បានសេចក្ដីចំរើនរុងរឿងទៅថ្ងៃមុខ ឧបមាដូចព្រះអាទិត្យដែលរះឡើងដូច្នោះ ។ កាលឃើញថាបានពេលាហើយ គេចាប់ត្រូវ-វាយឃ្មោះបន្លឺស្គរសព្ទឡើង ។ ត្រលាយកពេលានោះ លោកឲ្យលេងភ្លេងកិន្នរ ភ្លេងសារាយអណ្ដែត ភ្លេងសារាយវិលវង់ណាន ។

លុះបានពេលាហើយ គ្រូបង្វិលកូនប្រុសចេញពីទីនោះឡើងទៅសំពះផ្កាស្លានៅផ្ទះការ របៀបក្បួនវិហារនោះគឺ

បុរសម្នាក់កាន់ដាវទាំងស្រោមដើរមុខបង្អស់ បន្ទាប់ដោយលំដាប់មក អ្នកមហាតាំង ៣ នាក់ អ្នកកាន់ទៀន ២ នាក់ អ្នកកាន់ផ្កាស្លា ៣ នាក់ (១) អ្នកកាន់វង់ប្រាក់ ខាន់ស្លាប្រាក់ ស្នាប់ទឹកដោះ, គោធាប្ប, កូនប្រុស, មានអ្នកបាំងក្លស់ឬឆត្រឲ្យ ១ នាក់, ក្រោយបំផុតអ្នកភ្លេង ប្រគុំលេងភ្លេងនារី ភ្លេងស្តេចដើរ ។ វេលាហែរទៅ កូនប្រុសត្រូវមានប្រាក់យ៉ាងតិចត្រឹម ១ ស្លឹង ឬ មួយកាក់ជាប់ទៅនឹងខ្លួន ខណៈទៅដល់មាត់ជណ្ដើរផែនថ្មមួយ គេដាក់ទុកឲ្យកូនប្រុសឈរលាងជើង ហើយនឹងឃើញក្មេងប្រុស ១ នាក់ ជាប្អូនបង្កើត ឬ ជាញាតិជិតរបស់កូនស្រី កាន់ផ្តិលទឹកមកលាងជើងឲ្យ ហើយនឹងឲ្យស្លា ១ ម៉ាត់ ដែលដៃកូនស្រីសៀកឲ្យ កូនប្រុសទទួលស្លាស៊ី ហើយ ត្រូវឲ្យប្រាក់ដែលជាប់មកនឹងខ្លួនទៅក្មេងនោះ ហើយ

---

១– អ្នកកាន់ផ្កាស្លាច្បង ត្រូវយកបងប្រុសរបស់កូនប្រុស ១ កាន់ ឲ្យរើសញាតិដែលជិត ហើយជាអ្នកមានខាន់ស្លា ទាំងមិនអភ័ព្វ អ្នកដែលអាយុតិចជាងកូនប្រុសលោកហាមមិនឲ្យកាន់ ។

ក្មេងនោះ ត្រូវដឹកដៃកូនប្រុសឡើងដំណើរទៅ ។ ត្រង់នេះ មានទំនៀមអ្នកស្រុកខ្លះ ឬ មេបាខ្លះ គេសែនក្បាលដំណើរផង មានរណ្ដាប់គឺ បាយសីស្លាក ៤ មាន់ស្ងោរ ១ ឬ សាច់ជ្រូក ១ ដុំ រៀបដាក់ក្បែរក្បាលដំណើរ ហើយអុជទៀនធូបនៅក្បាលដំណើរ ជួនកាលមានអុជដាវផង (ទំនៀមនេះប្រហែលជាប់មកអំពីចិន) ហើយត្រូវសែនក្នុងវេលាមុនដែលកូនប្រុសនឹងមកដល់ ។ កូនប្រុសកាលឡើងដល់ល្វែងចិនហើយ ត្រូវអង្គុយម៉ែអន់ចាំមេបានិយាយការ ។ លំដាប់នោះ អ្នកមហាត្រូវដំណាបសួរមេបាថា លោកអ្នកណាដែលត្រូវទទួលផ្កាស្លា ច្បង-កណ្ដាល-ពៅ ។ មេបាត្រូវបង្ហាញខ្លួនថា នេះមួយៗឲ្យគ្រប់ទាំង ៣ នាក់ ។ ទំនៀមអ្នកទទួលផ្កាស្លា ត្រូវរើសយកពួកញាតិរបស់ស្រី ដូចយ៉ាងម្ដាយធំ ម្ដាយមីង បងស្រីបង្កើត ដែលជាអ្នកបានរៀបមង្គលការខាន់ស្លា នឹងមានកូនស្រករ រស់នៅទាំងគូ ។

លំដាប់នោះ  អ្នកមហាត្រូវប្រាប់ឲ្យកូនប្រុសសំពះស្លា
ព្រះពរ  គឺម្លូដែលរៀបមានចំនួន ៣ គ្រួយដាក់នៅលើខ្ទើយ
សំពះម្តងចាប់ស្លាព្រះពរឡើង ១  ហើយដាក់នៅវិញ  ទាល់
តែគ្រប់ទាំង ៣ គ្រួយ  រួចហើយឲ្យសំពះ ៣ ដងទៀត  ដល់
គ្រប់ការៈ ៣ ដង  ឲ្យផ្កាបាតដៃទាំងពីរ,  អ្នកដែលកាន់ផ្កា
ស្លាច្បង  ត្រូវយកផ្កាស្លានោះទៅដាក់លើដៃកូនប្រុស ៗ
ត្រូវជូនទៅអ្នកដែលត្រូវទទួល  ដែលមេបាប្រាប់កម្សាញមិញ
ឲ្យផ្ញើតែឈ្មោះ  ទាល់តែគ្រប់ផ្កាស្លាទាំង ៣ ។  អ្នកទទួល
ត្រូវទុកផ្កាស្លា  អ្នកភ្លេងត្រូវលេងភ្លេងព្រះថោង ។

លំដាប់នោះ  អ្នកជូនស្រីម្នាក់  ត្រូវអុជទៀនបិទនៅនេ
អ្នកជូនហើយ  ដំរាបមេបាសុំអនុញ្ញាតឲ្យកូនស្រី  ចេញមកអង្គុ
ចងដៃ  ហើយកាន់នៅនោះ  ចូលទៅអញ្ជើញកូនស្រីឲ្យដ៏
ខាងក្នុង ។  ខាងមេបាត្រូវបង្គាប់ឲ្យអ្នកមហាកំច្រៀង
អញ្ជើញកូនស្រីពីខាងក្នុងតាំងនេ  បើអ្នកមហាមិនចេះចាំច្រៀង

នឹងពិធីគេអ្នកឯណានិមួយជំនួសខ្លួនក៏បាន អ្នកច្រៀងត្រូវកាន់ផ្តិតកំច្រៀងទំនុកស្រីអន ៣ បទថា "អន្ទើយស្រីអន កាំបើកកាំនន សូមអនមហាថ្ងៃ សូមអ្នកកាំផ្តិត សូមអ្នកដឹកដៃ ស្រីអនមហាថ្ងៃ ពេលាបានហើយ អនចេញសំពះ កន្ទ្រាះគ្រមុំ ជួបជុំពេញផ្ទះ អនចេញសំពះទទួលព្រះពរ" ។

មានបទច្រៀង ១ បទទៀតឡេងគ្នាទាំង ៣ ដូច្នេះ :

បទទី ១ ថា អន្ទើយស្រីអន សុំបើកកាំនន ជូនអនដេកលក់ សុំឋាស់អនឡើង កេទឹកលុបមុខ ជូនអនដេកលក់ ស្រន៑ាកលើខ្នើយ ។

បទទី ២ ថា អន្ទើយស្រីអន សុំបើកកាំនន សុំអនមកផ្ទុំ អននឹងចេញមក អនដើរសន្សឹម អញ្ជើញអនផ្ទុំ ទន្ទឹមលើខ្នើយ ។

បទទី ៣ អន្ទើយជាត់ជាយ ជាត់ចេញឲ្យឆ្ងាយ

សោះកាសាន់កាន់ កន្ទុលខ្ទល់ខ្ទើយ យើងរៀបបំរុង សុំអនមកផ្ទឹម ពេលាបានហើយ (១) ។

លំដាប់នោះ អាចារ្យត្រូវអុជទៀនពពិល(២)ឡើងហើយ រើសយកប្រុស ៥ នាក់ ស្រី ៤ នាក់ ដែលជាអ្នកមានខាន់ស្លានីងមិនអភ័ព្វគូ ឲ្យមកអង្គុយដំកន់ជុំវិញអ្នកផ្ទឹម អាចារ្យត្រូវអង្គុយពីខាងមុខអ្នកផ្ទឹម ហើយផ្ដើមបង្វិលពពិល បណ្ដើរពពិលជាទក្ខិណាវដ្ដ គឺហុចបន្តគ្នាពីដៃស្ដាំទៅដៃឆ្វេង អា-ចារ្យត្រូវសូត្របរិកម្មបណ្ដើរនូវធម៌ជយន្ដោស្លូវេះ :

**ជយន្តោពោធិយាមូលេ សក្យានំនន្ទិវឌ្ឍនោ**
**ឯវំត្វំវិជយោហោហិ ជយស្សុជយមង្គលេ**

---

១ របៀបរៀនទាំង ៣ នេះ រៀនតែបែបណា១បានហើយ ។

២ លក្ខណៈពពិល ពពិលនោះគេសិតធ្វើពីស្ពាន់ តួពពិលសណ្ឋានដូចស្លឹកពោធិ៍ មានដងកានដូចសណ្ដាន់ស្លឹកពោធិ៍ ម្ខាងរលីង ម្ខាងមានរូបទេពប្រណម្យ គឺរូបទេវតាប្រណម្យដៃ, មានចំនួន៣ ។ វេលាដែលបង្វិលគេអុជទៀនបិទនៅកំពូលពពិល ហើយកាន់ដងហុចបន្ត ៗ គ្នាទៅ ។

អបរាជិតបល្លង្កេ　　សីសេបឋវិបោក្ខរេ
អភិសេកសព្វពុទ្ធានំ　　អគ្គប្បត្តោបមោទតិ
សុនក្ខត្តំ សុមង្គលំ　　សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោច　　សុយិដ្ឋំព្រហ្មចារីសុ
បទក្ខិណំ កាយកម្មំ　　វាចាកម្មំបទក្ខិណំ
បទក្ខិណំ មនោកម្មំ　　បណិធីតេ បទក្ខិណា
បទក្ខិណា និកត្វាន　　លភន្តត្ថេបទក្ខិណេ ។

ប្រែថា ព្រះសម្មាសម្ពុទ្ធកាលគង់នៅ លើអបរាជិតបល្ល័ង្ក ក្រោមដើមពោធិព្រឹក្ស ដ៏តាំងនៅកណ្តាលប្រថពីមណ្ឌល ដែលជាទីត្រាស់ដឹងនៃព្រះពុទ្ធគ្រប់ៗព្រះអង្គ ទ្រង់ផ្ចាញ់នូវមារនឹងសេនាមារឲ្យបាក់បបអស់ទៅ ទ្រង់ដល់នូវភាវៈជាបុគ្គលប្រសើរលើសទេវតានឹងមនុស្សទាំងឡាយ ធ្វើឲ្យពួកសក្យរាជរីករាយសប្បាយព្រះហឫទ័យ ខ្ញុំទៅយ៉ាងណាៗ អ្នកចូរឈ្នះ ចូរបាននូវជ័យមង្គលយ៉ាងនោះចុះ ។ បុគ្គលក្តី

មង្គលឫក្ស អរុនរះឡើងឫក្ស ខណៈឫក្ស យាមឫក្ស បូជាឫក្ស មានមកពីបុគ្គលប្រព្រឹត្តកាយវាចាចិត្ត ជាសុចរិត ទាំងអស់ កាយកម្មក្តី វចីកម្មក្តី មនោកម្មក្តី ដែលជា របស់ខាងស្តាំ គឺជាខាងល្អបរិសុទ្ធហើយ ដែលឲ្យសម្រេច របស់ដែលប្រាថ្នាជាខាងស្តាំ គឺខាងល្អ ហេតុនោះបុគ្គលគួរ គប្បីធ្វើកាយកម្ម វចីកម្ម មនោកម្ម ឲ្យជាខាងស្តាំ ក៏នឹង បាននូវផលជាខាងស្តាំដូចគ្នា ។

លំដាប់នោះ ឲ្យអ្នកមហា ឬអ្នកឯណាមួយដែលចេះ កំបើកបាយសី ( បាយស្រី ) ៣ បទ ដំបូងទៀនមិនទាន់ ទៀន កាំបន្ទិចទៅហើយ លូកទៅចាប់ដងដាវកាន់ឡើង ហើយស្រែកថា :

ជ័យហោង ឲ្យអ្នកទាំងពួងឆ្លើយថា ជ័យ.

សួស្តីហោង " " សួស្តី

សុខហោង " " សុខ

ហើយក៏ច្រៀងបទកិន្នរ ឬបទបន្ទាយយានយាស តទៅ ថា " ដាវអើយដាវដែក ដាវល្អចំឡែកបានពីសួគ៌នាយ ឪ ជាឪពុក ស្រោមសោតជាម្ដាយ បានពីសួគ៌នាយ កម្រាប សត្រូវ » ច្រៀង ៣ ដង ហើយស្រែកថា ជ័យហោង សួស្ដីហោង សុខហោង ដូចមុនទៀត រួចយកចុងដាវ ពាត់ស្បៃដែលគ្របទៀប ហើយក៏ច្រៀងតទៅទៀតថា " ទុ ស្បៃកាសា បានពីទេវតា លោកដាក់មកឲ្យ ពាយកស្បៃ រួចបាច់ទៀបជាក្រោយ លោកដាក់មកឲ្យ បានសុខសួស្ដី » ច្រៀង ៣ បទហើយស្រែក ជ័យហោង សួស្ដីហោង សុខ ហោងទៀត ។ រួចហើយឲ្យដាក់ទៅវិញ គឺដាក់ដងដាវ លើដៃកូនប្រុស ចុងដាវលើដៃកូនស្រី ។ រួចបាច់ឡើង ក៏ច្រៀងថា " ទុទៀបទាំងគូ ព្រឹមត្រូវលក្ខណា បានពី ទេវតា ឲ្យពរនាងនាក់ » ៣ ចប់ហើយឲ្យដាក់ទៀបទៅ វិញ ។ ក្នុងវេលាកំបើកបាយសី លោកឲ្យលេងភ្លេង

កិន្នរ ភ្លេងបន្ទាយយានយាស ។

លំដាប់នោះ អាចារ្យត្រូវសូត្រឲ្យពរផ្កាស្លា វេលាសូត្រចប់ឲ្យអ្នកភ្លេងលេងភ្លេងកន្ទង់ដោន (កន្ទង់មាស) ។ តអំពីនោះ ពួកមេបាត្រូវចងដៃកូនប្រុសស្រី ដោយអំបោះស ព្រមទាំងឲ្យសិរីពុសាធុការពររៀងខ្លួន ហើយគ្រាយផ្កាកណ្តាលនឹងផ្កាពោត ចែកឲ្យពួកញាតិបាចឲ្យពរដល់កូនប្រុសស្រី ។ ក្នុងខណៈនេះឲ្យអ្នកភ្លេងលេងភ្លេងបាយខុន ។ រួចហើយឲ្យកូនប្រុសស្រីងើបអង្គុយឡើង បែរមុខឈមទៅរកគ្នា ហើយក្រោកចូលទៅក្នុង កូនស្រីត្រូវចូលមុន កូនប្រុសចូលក្រោយ ឲ្យយកដៃចាប់ជាយស្បៃកូនស្រីចូលទៅ ។ ក្នុងខណៈនេះ ត្រូវវាយឃ្មោះ អ្នកភ្លេងត្រូវលេងភ្លេងលោមនាង ហើយប្រែជាភ្លេងបាយខុន ផាត់ជាយ ។

កាលកូនស្រីចូលទៅក្នុងហើយ អ្នកមហាត្រូវជំរាបមេបា សុំឲ្យកូនប្រុសស្រីទៅផ្ទឹមឯរោងផ្កាស្លា ។ តែកិច្ច

នេះអ្នកខ្លះធ្វើ អ្នកខ្លះមិនធ្វើ ។ អ្នកដែលធ្វើនោះ ដោយរបំណានរបស់គេ ដើម្បីនឹងប្រតិបត្តិតាមពាក្យដែលថា «តាកាហាវិកាហមង្គល» ដែលប្រែថា កូនប្រុសទៅការឯផ្ទះកូនស្រី, កូនស្រីទៅការឯផ្ទះកូនប្រុស (តាមប្រពៃណីប្រទេសឥណ្ឌាសម័យបុរាណ ) ដូចបានអធិប្បាយមកហើយខាងដើម យើងមិនឃើញធ្វើដូច្នោះ ឃើញហាក់ដូចជាមិនសមតាមឈ្មោះដែលហៅ ព្រោះពាក្យនេះគេតែងហៅក្នុងគ្នាតាំងគូដូច្នេះ ។

កាលផ្ទឹមចងដៃហើយ កូនប្រុសស្រី ត្រូវត្រឡប់ទៅផ្ទះការវិញ ចូលទៅផ្លាស់គ្រឿងសំអាងចេញ ស្លៀកពាក់ជាប្តីហើយចេញមកអង្គុយកណ្តាលជំនុំមេបា ក្រាន់ក្មេងនោះវិញ លំដាប់នោះ មេបាត្រូវចាត់ចែងយករណ្តាប់ស្លាប្រុសម្ខាងការធំ រណ្តាប់ស្លាប្រុសម្ខាងការកំណត់ រណ្តាប់ស្លាប្រុសម្ខាងជំនន តាមចំនួនដែលបានពោលហើយខាងដើម ចែកពួកញាតិចាស់ទុំយកទៅ ... គឺឃារដែលចែកពួកញាតិចាស់ទុំ

យកទៅនេះ គេហៅថា " គោះថង់វង់ ។

មានទំនៀមថា ស្លាប្រសប់មុខគោះថង់វង់ការធំនេះ ត្រូវបានដល់មា-មីងបង្កើតរបស់អ្នកលាមីខ្លួនទាំងសង្ខាង ។ ស្លាប្រសប់មុខគោះថង់វង់ការកំណត់ ត្រូវបានដល់មា-មីង ជីដូនមួយទាំងសង្ខាង ។ ក្នុងអ្នកកម្លោះនេះ បើអ្នកឯណាមួយគ្មានខ្លួន ឬជាបុគ្គលអភ័ព្វមិនគួរទទួលនឹងដាក់ឲ្យញាតិដទៃទទួលក៏បាន ។ ចំណែកឯស្លាកន្ទ្រង់ ជាស្លាសម្រាប់ទទួលពួកញាតិទូទៅ គ្មានប្រសប់មុខគោះថង់វង់ គឺចែកឲ្យចំពោះប្រុសឈ្មោះទេ ។

ក្រៅពីនេះ ពីដើមមានទំនៀមថា មាតាបិតាឬអាណាព្យាបាល ទាំងខាងកូនប្រុសទាំងខាងកូនស្រី ត្រូវនាំយកទ្រព្យទាំងពួង ដែលត្រូវចែកឲ្យកូនដែលរៀបការថ្មីនោះមកដាក់គរនៅទីចំពោះមុខប្រជុំញាតិ ទ្រព្យនេះហៅថា "គន់ទុន" គឺគំនរទ្រព្យជាដើមទុន ដែលមាតាបិតា និង

គប្បីចែកឲ្យកូនឱកាសនេះ ៗ ទ្រព្យនោះទាំងសន្ធាន ត្រូវថ្លៃឲ្យស្មើភាគគ្នា ឧបមាដូចយ៉ាងថា មាតាបិតាខាងប្រុសដាក់ប្រាក់ ១០០៛០០ មាតាបិតាខាងស្រីក៏ត្រូវដាក់ ១០០៛០០ ដែរ តែបើអ្នកម្ខាងជាអ្នកទាល់ក្រ អ្នកម្ខាងជាអ្នកស្តុកស្តម្ភ នឹងដាក់តិចច្រើនជាងគ្នា ទៅតាមធនធាននៃខ្លួនក៏បាន ។ ទ្រព្យណាដែលជាអចលនវត្ថុ គឺជាទ្រព្យដែលមិនអាចនឹងនាំយកមកបាន ដូចយ៉ាងស្រែចំការ ច្បារដំណាំ ជាដើម ត្រូវស្មើបញ្ជីកត់ត្រាចំណាំចំនួន នឹងតម្លៃនឹងចុះនាមកូនបញ្ជីនោះយកមកដាក់ ទ្រព្យណាជាចលវត្ថុដែលអាចនាំយកមកបាន ដូចយ៉ាងមាសប្រាក់ សំពត់ជាដើម ត្រូវនាំយកមកដាក់ ហើយស្មើបញ្ជីនោះប្រគល់ឲ្យរៀងខ្លួន ដោយមានក្រុមញាតិបានដឹងឮឃើញផង តែកិច្ចនេះមានឃើញច្រើនតែអ្នកមានសម្បត្តិថ្លៃ ៗ អ្នកដែលមិនបានចែកកូនឱកាសរៀបមង្គលការ គេចែកនៅវេលាការប្ដូ

ស្រេចហើយជាខាងក្រោយក៏មានច្រើន ។

# របៀបកាំសាកន្ទេល

សំដាប់ពីនោះ ត្រូវកាំសាកន្ទេល ។ របៀបកាំសាកន្ទេលនោះ លោកថាត្រូវម្ជុលមហាទី ២ កាំទៀន បើមិនចេះនឹងឲ្យទៅអ្នកណាមួយក៏បាន ។ អ្នកនោះត្រូវកាំបណ្តើរទៀនបណ្តើរ ហើយយកជើងម្ជុលកន្ទេល ១ ដែលគេក្រាលឲ្យកូនប្រុស-ស្រីផ្ទឹមនោះ កាលម្សៀបានហើយ ឲ្យចាប់លើកដាក់លើស្មា ទៀនសួរគេអ្នកណាជាម្ចាស់កន្ទេល ត្រូវការលោះឬទេ ? កន្ទេលនោះមានអនុភាពណាស់ ថាបើអ្នកណាលោះយកទៅដេកហើយ នឹងកើតមាសកើតប្រាក់ នូវខ្ញុំប្រុសស្រី គោ ក្របី ដំរី សេះ សម្បត្តិ សម្បូណ៌ ហៀរហូរមកដល់អ្នកនោះ គ្មានខ្វះអ្វី ។ ឲ្យអ្នកសាមីខ្លួនឆ្លើយសុំលោះ ដោយឲ្យប្រាក់ ១ បាទ ឬ ១ រៀលទៅអ្នកកាំ ។ ប៉ុណ្ណេះឈ្មោះថា ស្រេចកិច្ចកាំសាកន្ទេលហើយ ។

តែទំនៀមនេះគេបោះបង់ចោលជាច្រើនណាស់ទៅហើយ ។ ក្នុងខណៈកំនោះ អ្នកភ្លេងត្រូវលេងភ្លេងស្មោង ភ្លេងអុំទូក ។

កាលស្រេចតាំងសាកទុកហើយ ក៏ល្មមដល់ថ្ងៃត្រង់ ជាពេលត្រូវលាងកាយហារពួកញាតិមិត្រទាំងឡាយ កូនប្រុស-ស្រី ត្រូវចេញមកបំភើញៀវ ចាំថែមចយអាហារដល់ខ្លះទៀត ។ ក្នុងវេលាភ្ញៀវពិសាបាយ ឲ្យអ្នកមហាជិតាបសុំឲ្យមេឃ្លាបន្ទាប់កេណ្ឌកច្រៀង នឹងបន្ទាប់បទភ្លេង ៗ ទំនៀមបុរាណ ការច្រៀងជាភារៈលើសាស៊ីខ្លួនកូនប្រុសនឹងអ្នកមហាទី ២ តែកូនប្រុសច្រើនតែមិនចេះច្រៀង ហើយវេលានោះជាវេលាសម្រួម នឹងជាវេលាដែលឲ្យកើតអៀនខ្មាសច្រើន ហេតុនោះទំនៀមកូនប្រុសច្រៀងជូនមេបាស្តាប់ ទើបតាំងមិនឃាប់មកដល់សព្វថ្ងៃនេះ នៅមានតែក្បួនស្តីថាជាភារៈលើកូនប្រុសច្រៀងប៉ុណ្ណោះ ។ ចំណែកឯអ្នកមហានោះ អ្នកខ្លះចេះច្រៀងអ្នកខ្លះមិនចេះច្រៀង ហេតុនេះមុខច្រៀងកាំធ្លាក់

ទៅលើអ្នកភ្លេង    អ្នកមហាគ្រាន់តែជាអ្នកបរិយាយសួរមេបាថា ត្រូវការភ្លេងអ្វីឲ្យមេបាបន្ទាប់មក   អ្នកមហាក៏ទទួលប្រសាសន៍ ប្រាប់គេទៅអ្នកភ្លេងឲ្យច្រៀង   ឲ្យលេងភ្លេងតាមនោះ ។

តាមទំនៀមថា    អ្នកមហាទី ២ ជាអ្នកចាំជំរាបសុំឲ្យ មេបាបន្ទាប់ភ្លេង  នឹងទទួលប្រសាសន៍ហើយ   ប្រាប់គេទៅ អ្នកភ្លេង  មេបាត្រូវបន្ទាប់ភ្លេងដូចមានកាយឈ្មោះតទៅនេះ ៖

## ថ្លៃស៊ីកំណត់ ៣ ភ្លេង គឺ

១– ភ្លេងជូនដើមបទ

២– ភ្លេងជូនសម្ពត់

៣– ភ្លេងដោះក្រាយ

## ថ្លៃបង្ហើយឲ្យលេងភ្លេងតមកពីថ្លៃស៊ីកំណត់ គឺ

៤– ភ្លេងកន្ទេនក្រាំង

៥– ភ្លេងខ្មោះ

៦– ភ្លេងរបងមាស

៧- ភ្លេងបន្ទាយប្រាសាទ

៨- ភ្លេងទឹកជប់

៩- ភ្លេងក្រោមនាយ

ឯគ្រឿងភ្លេងនោះមិនបាច់លេងគ្រប់គ្រឿងទេ ឲ្យយកតែប៉ី ១ ទ្រ ១ និងអ្នកច្រៀងម្នាក់ប៉ុណ្ណោះ ។

កាលស្រេចកិច្ចកម្សាន្តនេះអស់ហើយ អ្នកសាមីដើមការ ត្រូវរៀបនំ ១ ថាសមកឲ្យអ្នកភ្លេងលេងភ្លេងក៏នៅពេលដែលហៅថា លេងភ្លេងលត់ចន្លុះ នៅពេលផ្កាស្លា ។ អ្នកភ្លេងត្រូវយកកន្ទុយចន្លុះ ១ មកដុត នាំគ្នាលេងភ្លេងមួយស្របក់ទៅហើយ ឲ្យរុះស្លឹកដែលប្រក់រោងចេញ ១ កណ្ដាប លំដាប់ពីនោះ អ្នកភ្លេងត្រូវយកទឹកមកលត់ចន្លុះ ប៉ុណ្ណោះ ហៅថា ស្រេចកិច្ចអ្នកភ្លេងហើយ ។

## ៨- របៀបផ្សំដំណេក

វេលាយប់ក្នុងថ្ងៃនោះ ក្នុងពេលម៉ោង ៨-៩ ត្រូវរៀប

ពិធីផ្សំដំណេក នៅទីកន្លែងដែលកូនប្រុសស្រីដេក គឺគ្រូរើសយកស្រីចាស់ ដែលមានអាយុច្រើន ហើយជាញាតិរបស់កូនស្រី ជាអ្នកមិនអភ័ព្វ ជាអ្នកចេះដឹងក្នុងរឿងនេះ ឲ្យជាអ្នកផ្សំដំណេក ។ កន្តុកដែលប្រើក្នុងពិធីនេះ គឺគ្រូយកត្រៀងផ្កាយសី ដែលពោលហើយខាងដើម និងថែមចំណាបមួយថាស បន្ទុំមួយថាស ម្លូវមួយ ។ គ្រូអុជទៀនធូបសែនដីជូនជីតា ដោយបន្ទុំចំណាបនោះហើយ ជួសទឹកដូងបញ្ចុកកូនប្រុស ៣ ស្លាបព្រា រួចបន្ទាប់ឲ្យកូនស្រីចាប់ចំណាបបញ្ចុកទៅកូនប្រុស ឲ្យកូនប្រុសបញ្ចុកទៅកូនស្រី ដើម្បីឲ្យស្រឡាញ់គ្នា ឋិតថេរអស់កាលទៅ និងឲ្យងាកទន្ទាំប្រដៅផ្សេងៗ តាមគួរហើយ ទើបឲ្យកូនប្រុសស្រីដេកទន្ទឹមគ្នា គឺឲ្យកូនប្រុសដេកខាងស្តាំ កូនស្រីដេកខាងឆ្វេង ប៉ុណ្ណោះហើយអ្នកផ្សំដំណេក ក្រោកនាំគ្នាចេញមកវិញ ។

ប៉ុណ្ណោះឈ្មោះថា ស្រេចការក្បួនអាពាហ៍ពិពាហ៍ហើយ ។

ក្រោយពីការហើយ ៣ ថ្ងៃ ត្រូវរៀបជូនប្ដីប្រពន្ធជាគូថ្មីនោះទៅសុំពរពីព្រះសង្ឃ ហើយកផ្កាស្លាម្លូរ នឹងចំណាប ១ ថាស បង្គុម ១ ថាស ស្លាធារ៍ ទៅវត្ត រីឯកូនប្រុសនោះធ្លាប់ទៅបួសរៀន បើវត្តនោះនៅឆ្ងាយណាស់លំបាកនឹងទៅ បុកូនប្រុសនោះមិនដែលបួសរៀននៅវត្តណាត្រូវទៅឯវត្តដែលមាននៅក្នុងស្រុកនោះ ។ លោកចៅអធិការទទួលផ្កាស្លានឹងសម្រាប់ហើយ សូត្រធម៌ឲ្យសព្ទសាធុការពរ ស្រេចហើយថ្វាយបង្គំលាមកផ្ទះវិញ ។

តាំងពីមានព្រះរាជបញ្ញត្តិ ឲ្យចុះបញ្ជីអាពាហ៍ពិពាហ៍មក ក្រោយពីរៀបការហើយ កាន់ ៣ ថ្ងៃ គេរមែងទៅបង្ហឹមន្ត្រីអត្រានុកូលដ្ឋាន សុំចុះបញ្ជីរៀបការ ក្នុងសៀវភៅអាពាហ៍ពិពាហ៍តាមច្បាប់ សម្រាប់ស្រុកផង ។

## ចប់ដោយពិស្តារ

# អាពាហ៍ពិពាហ៍មង្គល

## សង្ខេប

មានឯកសារជាច្រើន ថែងពីដើមកំណើតពិធីអាពាហ៍ពិពាហ៍មង្គលការខ្មែរ ដូចរៀបរាប់ខាងមុខនេះ ៖

ឯកសារខ្លះថា ៖ មង្គលការខ្មែរធ្វើតាមពិធីដែលព្រះមិថិលាមហាឫសីផ្សំផ្គុំព្រះរាម និងព្រះនាងសេតា និងធ្វើតាមពិធីដែលព្រះវេស្សន្ត ព្រះនាងមទ្រី ផ្សំផ្គុំចៅជាលីនិងនាងក្រឹស្នា ជាព្រះរាជបុត្រឲ្យជាគូស្រករ ។

ឯកសារខ្លះថា ៖ មង្គលការខ្មែរធ្វើតាមពិធីផ្សំផ្គុំព្រះថោងនិងនាងនាគបឋមក្សត្រខ្មែរ សម័យហ្វូណន (នគរភ្នំ) ដោយគេងដល់ចំណុចដែលកូនប្រុសតោងជាយស្បៃកូនស្រីចូលបន្ទប់ក្រោយពេលសំពះការ ថាធ្វើតាមដំណើរព្រះថោងតោងស្បៃនាងនាគចូលនគរ និងមានឱល់បទចម្រៀងឈ្មោះបទព្រះថោងនាងនាគ នាគព័ន្ធ ដែលអ្នកចម្រៀងតែងច្រៀងក្នុងពិធីមង្គល -

ការដាដាបតាំងពីព្រេងនាយមក ។

តាមការសន្និដ្ឋានឃើញថា ប្រពៃណីនៃពិធីមង្គលការខ្មែរយើង ប្រហែលជាបានចាប់កំណើតតាំងពីព្រះថោង-នាងនាគ សម័យនគរភ្នំ នោះមែន គ្រាន់តែចំណោះមក បុរាណាចារ្យថែមថយបញ្ចេញបញ្ចូលបន្តិចម្តង ៗ តាមកាលៈទេសៈ ប៉ុណ្ណោះ ជាប់ជាប្រពៃណីរៀងមកដរាបដល់សព្វថ្ងៃនេះ ។

ប្រពៃណីនេះ ចែកជា ៣ សម័យ គឺសម័យបុរាណ សម័យកណ្តាល និងសម័យបច្ចុប្បន្ន ។

ក្នុងទីនេះ សូមបរិយាយចំពោះសម័យកណ្តា... ឯកសារដែលមានគោលជា ៣ ថ្នាក់ គឺ :

ថ្នាក់ទី ១- ពេលមុនធ្វើអាពាហ៍ពិពាហ៍

ថ្នាក់ទី ២- ពេលធ្វើអាពាហ៍ពិពាហ៍

ថ្នាក់ទី ៣- ពេលក្រោយធ្វើអាពាហ៍ពិពាហ៍

## ថ្នាក់ទី ១– ពេលមុនធ្វើអាពាហ៍ពិពាហ៍

ពេលមុនធ្វើអាពាហ៍ពិពាហ៍មាន ៤ ផ្នែកគឺ

### ផ្នែកទី ១ មើលលមពង្សឆ្នាំ សមពង្សធាតុ

របៀបមើលឆ្នាំ មើលធាតុ គឺមើលតាមក្បួនដែលស្ដីពីពង្សយក្ស ពង្សមនុស្ស ធាតុទឹកជាដើម ធាតុដីឲ្យត្រូវគ្នាល្អ ។

### ផ្នែកទី ២ បែបូរ

កាលមើលខែ-ឆ្នាំ មើលធាតុ និងមើលចរិយាខាងស្រីឃើញថាល្អមហើយ ខាងប្រុសគេរកអ្នកមានតួស្រករដែលរស់នៅទាំងគូ មានខាន់ស្លា មានប្រាជ្ញាប៉ាំងធី ជាញាតិ ឬជាអ្នកស្និទ្ធស្នាលនឹងមាតាបិតា ឬអាណាព្យាបាលខាងស្រី ឲ្យទៅស៊ើបការស្ទាបស្ទង់មើល ៣ លើក :

លើកទី ១ មានកញ្ចប់ស្លាម្លូ ថ្នាំ កំដរដៃទៅជូនមាតាបិតា ឬអាណាព្យាបាលខាងស្រី ហើយនិយាយបញ្ជៀតបញ្ជៀង លោកស្ដេចអ្នកនោះនិយាយនឹងខ្ញុំថា ចង់មកលេង

នឹងលោកអ្នក តើលោកអ្នកថាម៉េច ? កាលបើខាងស្រីគេបើកឲ្យហើយ អ្នកចែចូវត្រឡប់មកប្រាប់ខាងប្រុសវិញ ។

លើកទី ២ មានរបស់កំដរដៃដូចមុន ស្លូកតែនិយាយចេញឈ្មោះថា លោកនេះអ្នកនោះពឹងខ្ញុំឲ្យមកជំរាបថា ចង់មកលេងនឹងលោកអ្នកខ្លាំងណាស់ ដោយឮដំណឹង ថា លោកអ្នកមានស្រែស្រុកសំបុកជើងលានល្អ គេចូលចិត្តចង់យកពូជស្រូវគន់មកបណ្តុះនៅស្រែនេះ ក្រែងមានផ្លែផ្កា តើលោកអ្នកថាម៉េច ? ខាងស្រីថា ចាំស្តាប់ការមើលសិន ។ អ្នកចែចូវក៏ត្រឡប់មកប្រាប់ខាងប្រុសវិញ ។

លើកទី ៣ មានស្លាម្លូក្រែលដាន់មុន ដាក់តោកបូរង់ ១ គូ ឲ្យអ្នកចែចូវយកទៅកំដរដៃដូចមុន ។ កាលជូនមាតាបិតា ឬអាណាព្យាបាលខាងស្រីរួចហើយជំរាបថា លោកនេះអ្នកនោះ ឲ្យខ្ញុំមកជំរាបថា សូមលោកអ្នកមេត្តាដោយម៉េនមកយូរហើយថា នឹងយកពូជស្រូវគន់ឯនោះ មកបណ្តុះ

នៅស្រែស្រុកសំបុកជើងលានឯនេះ តើអ្នកទុកផ្លូវឲ្យដើរ ទុកជណ្ដើរឲ្យឡើងដែរឬដូចម្ដេច ? កាលគេបើកផ្លូវឲ្យដើរ ជណ្ដើរឲ្យឡើងហើយ អ្នកចែចូវសួរខែឆ្នាំកំណើតកូនស្រី ។ គេប្រាប់ខែ-ឆ្នាំហើយ អ្នកចែចូវក៏ត្រឡប់មកប្រាប់ខាងប្រុសវិញ ។

## ផ្នែកទី ៣ ដណ្ដឹង

កាលចែចូវដឹងទំនាយហើយ គេឲ្យទៅដណ្ដឹង ៣ ជើងទៀត :

ជើងទី ១ គេឲ្យម្នាក់ទៅជូនពត៌មានដល់អ្នកគ្រប់គ្រងកូនស្រីជាមុនថា : លោកនេះអ្នកនោះនឹងឲ្យអ្នកផ្ញើមកដណ្ដឹងកូនស្រីលោកអ្នក តើឲ្យគេមកថ្ងៃណា ? កាលបានកំណត់ថ្ងៃហើយ គេពឹងស្រី ៣ នាក់ឲ្យជាអ្នកជូនទៅដណ្ដឹង ដោយមានថាសនំ ១ គូ ស្លា ម្លូ ថ្នាំ ស្លាជ្វា ចេកទុំ អន្សម នំគម នំចក់ រៀបជាគូៗទៅជូនខាងស្រីនិយាយថា : លោកនេះអ្នកនោះបានពឹងខ្ញុំទាំង ៣ នាក់ ឲ្យមកសូមដណ្ដឹងនាងនោះ ជា

កូនលោកឲ្យជាភរិយានាយកនោះជាកូនគេ ។ បើលោកអ្នកមេត្តានឹងជូនបណ្ដាការតាមត្រូវការ ។ ខាងស្រីថា ចាំសួរមេបាសិន ជើងក្រោ[illegible]មជីវ

ជើងទី ២ កាលឲ្យអ្នកផ្លូវទៅដណ្ដឹងមួយលើងឃើញថាពុំទាន់ស្រេច គេទៅដណ្ដឹងជើងទី ២ ទៀត គេដណ្ដឹងកំណត់ថ្ងៃដូចមុន កាលបានកំណត់ថ្ងៃ-ខែហើយ គេចាត់ចណ្ដាប់មានថាសនេ ១ គូ មានកន្សែងប្រមុចក្រាលពីលើ មានស្លាម្លូ ថ្នាំ ស្លាផ្លា ទៀន ១ គូ. ស្រា ១ ដប ចេកនុំ អន្សម នំគម នំបត់ នំបង់ឡាញ់ ឲ្យអ្នកផ្លូវ ៣ នាក់យកទៅជូនខាងស្រីនិយាយថា លោកនេះអ្នកនោះបានពីរដូនាំង ៣ ឲ្យមកសូមដណ្ដឹងដូចមុន បើលោកមេបាអនុញ្ញាតឲ្យ នឹងជូនបណ្ដាការតាមត្រូវការ ។ ខាងស្រីថា អ្នកផ្លូវនេះជាស្រី ត្រូវទទួលការគ្រប់ជំពូកមិនបាន មួយទៀតយើងពុំទាន់ស្គាល់កូនប្រុសរបស់អ្នក ត្រូវអ្នកឲ្យប្រុស ៗ មក ឲ្យយកចាំងកូនប្រុសមក

ឲ្យយើងមើលចង់ បែបនេះហៅថា ស៊ីស្លាកនៀង ។

ជើងទី ៣ គេឲ្យអ្នកផ្លូវទៅដណ្ដឹងឲ្យដាច់ស្រេច ។ មុននឹងទៅ គេជូនពត៌មានដល់ខាងស្រីជាមុន ។ កាលខាងស្រីប្រាប់កំណត់ពេលហើយ ខាងប្រុសគេរកអ្នកផ្លូវស្រី ៣ នាក់ ប្រុស៣នាក់ ចាស់២នាក់ ក្មេង១នាក់ ហៅថា"មហា" ឲ្យនាំរណ្ដាប់ មានចង់សេ១គូ ស្លា ម្លូ ផ្កាំ ស្លាផ្កា ទៀន ស្រា ចេក នំ អន្សម នំគម នំបត់ នំបន្ទាញ់ នំកន្ត្រំ នំក្រូច អង្ករ ត្រី សាច់ បន្លែ នឹងផ្លែឈើផ្សេងៗ ជាគូៗ ព្រមទាំងគ្រឿងមាសពេជ្រ នឹងគ្រឿងស្លៀកពាក់ ទៅជូនខាងស្រី ជារបស់បញ្ចុំចិត្ត ។ លុះជួបជុំហើយ អ្នកផ្លូវពាក់អាវពណ៌ក្រហម ជំរាបមេបាថា : លោកអ្នកឈ្មោះនេះបានពឹងខ្ញុំឲ្យនាំបណ្ដាការ មកជូនលោកមេបា សូមនិយាយបណ្ដាការ ហើយក៏និយាយតាមទម្លាប់ហូរហែទៅ ។ ចប់ហើយមានការបង្ហាញរូបកូនប្រុស កូនស្រីដល់ទីប្រជុំ ។ បែបនេះហៅ

ជ. ស៊ីស្លាបញ្ជាប់ពាក្យ ។

សម័យបុរាណ កាលស៊ីស្លាបញ្ជាប់ពាក្យហើយ គេតែងឲ្យកូនប្រុសទៅបំរើម្ដាយក្មេក ឪពុកក្មេក ដរាបដល់ពេលរៀបការ ។

## ផ្នែកទី ៤ ជូនជំនួន

របៀបជូនជំនួន តាមទំនៀមបុរាណក្នុងក្បួនទម្រង់ការដែលព្រះជ័យជេស្ឋាមហាឥស្សរ ទ្រង់តែងទុកនោះ ជាត្រូវបន្ទាប់ដូច្នេះ :

| | |
|---|---|
| បណ្ដាការធំ | រណ្ដាប់ស្លាជ័យ |
| បណ្ដាការស្លាកំណត់ | រណ្ដាប់ប្រុសតូមុខការធំ |
| បណ្ដាការសាជនីរង | រណ្ដាប់ប្រុសតូមុខការកំណត់ |
| បណ្ដាការស្លាកន្សែង | រណ្ដាប់ប្រុសតូមុខគោះជនីរង |
| បណ្ដាការស្លាដក់ | ចំនួនប្រាក់ខាន់ស្លា |
| រណ្ដាប់ស្លាព្រះពរ | ប្រាក់ស្លាប់ទឹកដោះ |

ក្បួនទម្រង់ការនោះ មានតាមចំនួនបណ្ណាការ ចំនួនរណ្ដាប់ដូចរៀបរាប់ខាងលើ ការជូនជំនួនគេតែងជូនតាមរបៀបនេះ ។

ថ្នាក់ទី ២- ពេលធ្វើអាពាហ៍ពិពាហ៍ :

ពិធីអាពាហ៍ពិពាហមង្គលការខ្មែរ សម័យបុរាណមាន៣ថ្ងៃ គឺ ក- ថ្ងៃទី ១ ចូលរោង ខ- ថ្ងៃទី ២ ស៊ីកំណត់ គ- ថ្ងៃទី ៣ សំពះ ដូចរៀបរាប់តទៅនេះ :

ក)- ថ្ងៃទី ១ ចូលរោង ក្នុងថ្ងៃនេះ អ្នកធ្វើការខាងប្រុស គេប្រមូលញាតិមិត្តនាំបណ្ណាការផ្សេងៗ ទៅផ្ទះការនិយាយសុំអនុញ្ញាតកិច្ចការផ្សេង ៗ អំពីមេបាខាងស្រី គឺសុំជណ្ដើរឡើង សុំព្រៃកន្ទុស សុំកំពង់ដងទឹក សុំដីជីកក្រុក ជីកជើងក្រាន សង់តៅផ្កាស្លា សង់ពានទេពតា សុំនាំសាមីខ្លួន និងភស្ដុភារបណ្ណាការមកចូលរោងការ ហើយចេះចាត់ចែងកិច្ចការសព្វគ្រប់តាមទំនៀមតទៅ ។

១)- ថ្ងៃទី២ស៊ីកំណាត់ ក្នុងថ្ងៃនេះម៉ោង ៧ ព្រឹកគេ សែនដូនតាស៊ីស្លាកំណាត់ ។ ថ្ងៃរសៀលគេកាត់សក់ឲ្យកូនប្រុស-ស្រី បើកូនស្រីទុកមួយ គេកាត់តែខាងកូនប្រុស ។ ហែកូនប្រុសទៅក្រាប់ផ្ទះតាចាស់ស្រុកដល់ខ្ទម ធ្វើពលិការក្រុងពាលីក្បែរពេនផ្កាស្លា ។ សូត្រមន្តទៀនគ្នា ប្រុសនៅពេនផ្កាស្លា ស្រីនៅផ្ទះការ ប្រុសត្រូវគ្នានៅផ្ទះការតែម្តង ។ ម៉ោង ៧ យប់លៀនគៀន ។ ម៉ោង ១០ យប់ គេយកស្រីជំទង់ ៤ នាក់ ប្រុសជំទង់ ៤ នាក់ នឹងមហាជំ ២ នាក់ ឲ្យរៀបផ្លែឈើ គឺខ្ចប់នំជាកញ្ចប់ៗទុកជូនមេបា ម៉ោង ១២ យប់គេបុកល្អិត ធ្វើល្អេញ ជាវិប្បកាត់ខាន់ស្លា ជាប្រាក់ស្ទូវ ១ ណែន ទម្ងន់ ១៦៛០០ ។ ទៀបភ្លឺគេរកស្រី ៣ នាក់ ដែលមានគូស្រករនៅរស់ មានខាន់ស្លា ឲ្យរៀបដោតផ្កាស្លា ដោយយកខ្លួរស្លាដែលដាក់សូត្រមន្តពីថ្ងៃរសៀលនោះ មកដោតផា ៣ ដុំ គឺផ្កាស្លាទី១ ដោតស្លា ២១ ផ្លែ ម្លូ ២១ សន្លឹក

តាមចំនួនគុណឪពុក ទី ២ ដោតស្លា ១២ ផ្លែ ម្លូ ១២ សន្លឹក

តាមចំនួនគុណម្ដាយ ទី៣ ដោតស្លា ៦ ផ្លែ ម្លូ ៦ សន្លឹក

តាមចំនួនគុណមន ។ ល ។

ក)- ពិធីទី ៣ សំពះ ក្នុងថ្ងៃនេះវេលាភ្លឺស្រាងៗ អាចារ្យកាន់ពាលា នាំកូនប្រុសសំពះពានទេវតា នៅមុខរោងផ្កាស្លា ឲ្យអង្គុយលើក្បាលផ្កាប់ក្រៅអ៊ីចាំពេលា នៅទីនោះ ដល់ហើយគេដង្ហែកូនប្រុសទៅសំពះនៅផ្ទះការ ពេលនោះកូនប្រុសស្លៀកសំឡុយ ពាក់អាវផាយ កូនស្រីបួងសក់ពាក់វៃ ពាក់ស្បៃ ទោះបីពីដើមធ្លាប់កាត់សក់ ដល់ពេលសំពះនេះ គេតែងរកចំណាងសក់មកចងបួងជាថ្មីហើយគេឲ្យញូតដៃ ផ្ទឹមសំពះ អ្នកគ្រៀងកាន់ដាវរាំបើកច្បាយមុន ស្បូរពីជ័យហោង សួស្តីហោង មែនហោង សំពះរួចកូនស្រីដើរឡើងឈមមុខកូនប្រុស កូនប្រុសតោងជាយស្បៃកូនស្រី ចូលបន្ទប់ ផ្លាស់សំលៀកបំពាក់ថ្មី ហើយចេញមកអង្គ

កណ្ដាលទីប្រជុំវិញ ៗ លំដាប់នោះមានការកាន់ដាវទ្រៀន កាំស្លាកន្ទេល ហើយគេនាំកូនប្រុស - ស្រីទៅផ្ទឹមនៅកោនផ្កាស្លាទៀត ដើម្បីតម្រូវតាមពាក្យថា អាវាហមង្គល នាំស្រីទៅការឯផ្ទះប្រុស វិវាហមង្គល នាំប្រុសទៅការឯផ្ទះស្រី រួចហើយគេរៀបសៀនភ្ញៀវ នៅព្រឹកនោះទៀត ៗ សម័យបុរាណ គេរៀបសៀនភ្ញៀវធំ ២ លើក នៅល្ងាចថ្ងៃស៊ីកំណត់ ១ លើក ព្រឹកថ្ងៃសំពះមួយលើក ៗ

ពេលយប់ក្នុងថ្ងៃសំពះ វេលាម៉ោង ៧-៨ យប់ គេរៀបពិធីផ្សំដំណេក នៅទីកន្លែងកូនប្រុស-ស្រីដេក ៗ ពិធីនេះគេយកស្រីចាស់ៗ ២នាក់ ជាញាតិខាងកូនស្រី ជាអ្នកមិនអកីឡគួ ចេះដឹងរឿងនេះ ឲ្យជាអ្នកផ្សំដំណេកឲ្យ ដោយមានចំអាបមួយចាន ចេកទុំមួយចាន ដូងខ្ចីមួយ បាយសី ១ គេអុជទៀនធូបសែនជូនតា ហើយជូនទឹកដូងបញ្ចុកកូនប្រុស ៣ ស្លាបព្រា កូនស្រី ៣ ស្លាបព្រា រួចឲ្យកូនស្រីយកចេកបញ្ចុកកូន

ប្រុស កូនប្រុសបញ្ចុកកូនស្រី ជានិមិត្តរូបនៃការឲ្យចេះស្រឡាញ់គ្នា រហូតមួយជីវិត រួចហើយចាស់ៗនាំគ្នាចេញ ។

## ថ្នាក់ទី ៣- ក្រោយពេលធ្វើអាពាហ៍ពិពាហ៍

ក្រោយពីថ្ងៃសំពះបីថ្ងៃ គេនាំគូស្វាមី ភរិយាថ្មី យកផ្កាស្លាឡ្យង នឹងចំអាបមួយចាស បន្លែមួយចាស ស្លាធុរី ទៅថ្វាយមន្តសុំពរពីព្រះសង្ឃឯវត្ត ឲ្យលោកបាចផ្កាស្លានោះ ប្រសិទ្ធិពរឲ្យបានសុខចម្រើនតទៅ ។

ជាពិសេស ថ្ងៃក្រោយៗមកទៀត គេនាំកូនប្រុស-ស្រី ទៅសួរញាតិជិតឆ្ងាយ ទាំងខាងប្រុស ទាំងខាងស្រី ដើម្បីឲ្យញាតិបានស្គាល់ ។

ចប់ដោយសង្ខេប ។

# ប្រភពនៃពិធីខ្លះក្នុងមង្គលការ

## ប្រភពនៃការតោងជាយស្បៃកូនស្រីចូលបន្ទប់

ព្រះថោងបឋមក្សត្រខ្មែរ កាលដែលទ្រង់បានជាធំលើផែនដីកោះគោកធ្លកហើយ ទ្រង់នាំសេនាចុះទៅក្រសាលលើផ្នកខ្សាច់ឆកឈូងសមុទ្រនៃកោះនោះ នៅពេលទឹកនាច ៗ ដល់ពេលទឹកជោរ ទ្រង់ឡើងមកពុំទាន់ ទ្រង់ផ្ទុំនៅលើកោះនោះចាំទឹកនាចទៅវិញ ។ វេលាពាក់កណ្ដាលអធ្រាត្រ នាងបុត្រីស្ដេចនាគបាននាំបរិវារមកនិម្មិតខ្លួនជាស្រីមនុស្ស មកក្រសាលនៅទីនោះដែរ ។ ព្រះថោងសព្វព្រះទ័យ ទ្រង់ចូលទៅលោមនាង ៗ ថាចាំទៅទូលបិតាសិន ។ កាលបិតាអនុញ្ញាតឲ្យនាងនាំព្រះថោងទៅនាគពិភព នាងក៏ឲ្យព្រះថោងតោងជាយស្បៃនាងចូលទៅ ទើបចូលទៅបាន ទៅដល់ហើយស្ដេចនាគបានអភិសេកផ្សំផ្គុំព្រះថោងនឹងនាងនាគ ឲ្យជាស្វាមីជាឧត្តមមហេសី ហើយឲ្យត្រឡប់មកគ្រប់គ្រងនគរភ្នំ គឺនគរ

គោកធ្លក ជានគរខ្មែរដំបូងនេះវិញ ។

ដំណពីនោះមក អ្នកស្រុកទាំងពួង វេលាធ្វើមង្គលការ គេប្រគំភ្លេងព្រះថោងនាងនាគ នាគព័ន្ធ និងពេលសំពះរួច គេឲ្យកូនប្រុសតោងជាយស្បៃកូនស្រីចូលបន្ទប់ ជាប់ជាប្រពៃណី រៀងរហូតមកដល់សព្វថ្ងៃនេះ ។

## ប្រភពនៃការកាន់ដាវសំពះការ និងរាំសាកស្តុល

ពីព្រេងនាយ មានអាមាត្យម្នាក់ជារាជបម្រើ ទៅបង្ក្រាបពួកបះបោរនៅស្រុកជនបទ ។ អាមាត្យនោះទៅដល់ស្រុកមួយ បានដណ្តឹងនាងកញ្ញាម្នាក់កូនអ្នកស្រុកនោះជាប្រពន្ធ បានឲ្យមាសមួយដម្លឹង ជាគ្រឿងបញ្ជាប់ពាក្យ សន្យាថាបីខែទៀតនឹងមករៀបការ ។ អាមាត្យនោះត្រឡប់ទៅក្រុងវិញ មានកិច្ចការរាជការច្រើនក៏ខកខានដល់បីឆ្នាំ ។ ដោយយល់ថាហួសសន្យាទៅហើយ ម្តាយឪពុកក៏ឲ្យកូននោះទៅកម្លោះម្នាក់ទៀតដែលដណ្តឹងក្រោយ ។ កំពុងតែសំពះការ អាមាត្យ

នោះទៅដល់ ក៏ហូតដាវកាប់កម្លោះនោះស្លាប់នៅកន្លែងសំពះ ហើយយកនាងនោះជាប្រពន្ធទៅ ។ សម្លាប់ហើយភ្លាម ម្តាយឪពុកអញ្ជើញព្រាហ្មណ៍មកស្រុកស្តី លាន់ឈាម សាកខ្មុលរម្ងាប់ចាំព្រៃ ។

តពីនោះមក អ្នកស្រុកតំណាលថាដាវដាវគ្រាកាចកំចាត់ សត្រូវកុំនពេលទៀមន្តលោកការទាន ក៏យកដាវមកឲ្យកូនសំពះ ការ និងឲ្យអ្នកទៀងកាន់ដាវកាំភ្លៃទំនុកសាកខ្មុល រម្ងាប់ ចាំព្រៃដាប់ជាប្រពៃណីដល់សព្វថ្ងៃនេះ ។

## ប្រភពនៃផ្កាស្លាបី

ពីព្រេងនាយ មានកុមារកំសត់ ៤ នាក់ បានទៅ រៀនសិល្បសាស្ត្រអំពីតាតារ្ទិសាបាមោក្ខ ម្នាក់រៀនទាយ ម្នាក់រៀនបាញ់ ម្នាក់រៀនមុជទឹក ម្នាក់ទៀតរៀនប្រស់ ។ រៀនចេះហើយក៏ត្រឡប់មកស្រុកវិញ លុះមកដល់មាត់សមុទ្រ កុមារចេះទាយ បានទាយថា ព្រឹកនេះនឹងមានសត្វហត្ថលិង្គ

ពាំព្រះរាជបុត្រីមួយអណ្ដែតមកដល់ទីនេះ ។ កាលឃើញមក មែន កុមារចេះបាញ់ បានបាញ់ធ្លាក់ទៅក្នុងទឹកស្លាប់ កុមារចេះមុជទឹក បានមុជទៅស្រង់នាងមក កុមារចេះប្រស់ បានប្រស់ឲ្យនាងរស់ឡើង ។ លុះរស់ឡើងហើយអ្នកទាំង ៤ នាក់ ដណ្តើមចង់បានធ្វើជាប្រពន្ធរៀងខ្លួន ។ ពេលនោះ ពោធិសត្វកាត់សេចក្តីថា កុមារចេះទាយត្រូវបានជាឪពុក ចេះប្រស់ត្រូវបានជាម្តាយ ចេះបាញ់ត្រូវបានជាបង ចេះមុជទឹកត្រូវបានជាប្តីនាង ព្រោះគេបានបីនាងពីក្នុងទឹកមក ។ អ្នកទាំង ៤ នាក់ ព្រមទទួលហើយ សុំឲ្យពោធិសត្វកាត់ចែងវត្តមួយ ទុកសម្រាប់ឲ្យកូនប្រសាគោរពមាតាបិតា នឹងបងព្រមទាំងញាតិក្នុងពេលធ្វើមង្គលការ ។ ពោធិសត្វសម្រេចថា ត្រូវយកផ្កាស្លា ១ ខ្នរ មកដោតជា ៣ ដុំ ។ ទី ១ ជាផ្កាស្លាច្បង សម្រាប់ឪពុក ទី ២ សម្រាប់ម្តាយ ទី ៣ សម្រាប់បងទទួល ៕

តពីនោះមកក៏មានផ្កាស្លា ៣ ក្នុងពិធីមង្គលការជាប់ជាប្រពៃណីដល់សព្វថ្ងៃនេះ ។

# ប្រភពនៃពពិល

ព្រះឥសូរឋិតនៅភ្នំកៃឡាស មានបុត្រទិព្វខ្លាំងពូកែ ស្មើតែអង្គជាតព្រះអង្គ នឹងយោនីនាងឧមាភគវតីជាមហេសីក៏ពូកែសក្តិសិទ្ធណាស់ ។ សម័យមួយ ព្រះឥសូរមេត្តាព្រះជ័យសុរិយារាជកុមារនៅនគរកៃកេកុដម្ពូ នាជម្ពូទីប ដែលត្រាច់ស្វែងរករៀនសិល្បសាស្ត្រ បានទ្រង់ស្តោះទឹកព្រះឱស្ឋដាក់ព្រះឱស្ឋនៃព្រះរាជកុមារនោះ ឲ្យមានកម្លាំងដូចដំរីសារហើយទ្រង់ប្រសិទ្ធីដីខ្សាច់ពីភ្នំចក្រវាឡជាស្លឹកពោធិមាស តំណាងយោនីនាងឧមា និងថ្មពេជ្រពីភ្នំហិមាល័យ ជាទៀនពេជ្រតំណាងអង្គជាតិព្រះអង្គ សុទ្ធតែឈ្មោះថា ពពិលរតន៍ ប្រទានដល់ព្រះជ័យសុរិយា ឲ្យយកទៅឲ្យអ្នកស្រុកបិទទៀនបង្វិលបក់ផ្សែងចូលក្នុងពិធីមង្គលទាំងពួង មានមង្គលការជាដើម ។

តពីនោះមកក៏មានពិធីបន្ទិលពាំពាល់ក្នុងពិធីផ្សេងៗ រាប់ជាប្រពៃណីដល់មកសព្វថ្ងៃនេះ ។

## ប្រភពនៃពាក្យបា ជ័យហោង សួស្ដីហោង

កាលពីព្រេងនាយ មានក្មេងស្រីម្នាក់កំសត់ឥតឪពុក មានតែម្ដាយ ។ សម័យមួយ ជាពេលស្រុកកើតទុរ្ភិក្សអត់បាយ នាងទៅស្វែងរកមើមឈើជាមួយអ្នកស្រុក ដល់ពេលស្រេកទឹកនាងបានផឹកទឹកនោមដំរី ដែលដក់នៅនឹងស្នាមជើងដំរី១ ដោយសំគាល់ថាទឹកល្អ ។ ផឹកហើយនាងក៏មានផ្ទៃពោះ ប្រសូតមកជាកូនប្រុស ឲ្យឈ្មោះថា ជ័យ ។ ក្រោយពីនោះ នាងមានប្ដីបានកូនប្រុសមួយទៀត ឲ្យឈ្មោះថា សួស្ដី ។

គ្រានោះ ស្ដេចក្នុងនគរនោះទ្រង់ព្រះទីវង្គតទៅគ្មានព្រះរាជបុត្រដំណរវង្ស អ្នកនគរនាំគ្នាធ្វើពិធីផ្សងដំរី ដើម្បីរកអ្នកមានបុណ្យធ្វើស្ដេច ដំរីទៅក្រាបនៅត្រង់មុខជើងជ័យ នឹង

សួស្ដី ដែលកំពុងដេកក្រោមដើមឈើមួយ ៗ គេ ឃើញសំគាល់ថា ជ័យ នឹងសួស្ដី ជាអ្នកមានអកំនិយារ គួរសោយរាជ្យ ក៏អញ្ជើញមកសោយរាជ្យ អភិសេកជ័យ ជាស្ដេច សួស្ដីជាឧបរាជ ៗ ក្នុងពេលដែលអភិសេក នោះ គេក្រែកប្រកាសថា ជ័យហោង សួស្ដីហោង មែនហោង គ្រប់ពារៈ ៣ ដង ទើបស្រោចទឹក ៗ

ដោយហេតុជ័យ សួស្ដី ជាអ្នកមានអំណាច ហើយ ពាក្យថា ជ័យ សួស្ដី ជាពាក្យមង្គលផង ទើបគេយកមក ប្រើក្នុងមង្គលការ ជាយកមកដល់សព្វថ្ងៃ ៗ

ចប់